# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

១៦-៦-២០០៦ -ព្រះរាជក្រម នស/រកម/០៦០៦/០១៥ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងកិច្ចព្រមព្រៀងអាស៊ានស្តីពីការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ៤៤២១

២៣-៦-២០០៦ -ព្រះរាជក្រម នស/រកម/០៦០៦/០១៦ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ៤៤៧១

### ២~ព្រះរាជក្រឹត្យ

១៦-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជុង ហៀន់វូ** (JEONG HYUN WOO) ជនជាតិកូរ៉េ សញ្ជាតិ កូរ៉េ កើតនៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៤៤៧៤

១៦-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជេរ៉ាល់ ត្រេវើ** (Gerald Trevor) ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស កើតនៅក្រុងបើខាំស្ទែត ប្រទេសអង់គ្លេស ៤៤៧៥

១៦-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦៨ ស្តីពីការតែងតាំង ឯកឧត្តម **ហ៊ុល ម៉ុនថា** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤៤៧៦

១៦-៦-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៦០៦/២៦៩ ស្តីពីការតែងតាំង ឯកឧត្តម **ថាវ គឹមហោ** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម **យ៉ុះ ហុកគ្រី** អនុប្រធានទី ២ រដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ៤៤៧៧

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

៣០-៦-២០០៦ -អនុក្រឹត្យលេខ ៤៥៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៤៧៨

៣០-៦-២០០៦ -អនុក្រឹត្យលេខ ៤៥៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៤៨៣

៣០-៦-២០០៦ -អនុក្រឹត្យលេខ ៤៥៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ៤៤៩១

០៣-៧-២០០៦ -អនុក្រឹត្យលេខ ៤៦០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤៤៩៣

០៤-៧-២០០៦ -អនុក្រឹត្យលេខ ៤៦១ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយស ៤៤៩៤

០៤-៧-២០០៦ -អនុក្រឹត្យលេខ៤៦២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ និង មេដាយការងារ ៤៤៩៦

០៤-៧-២០០៦ -អនុក្រឹត្យលេខ ៤៦៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៤៤៩៩

## ២-សេចក្តីសម្រេច

៣០-៦-២០០៦ -សេចក្តីសម្រេចលេខ ២៧ សសរ ស្តីពីការតែងតាំងសមាសភាព នៃលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ៤៥០០

## ៣-សារាចរណែនាំ

២៩-៦-២០០៦ -សារាចរណែនាំលេខ ០៦ សរណន ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ៤៥០២

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០៩-៦-២០០៦ -ប្រកាសលេខ ១៨៥ ប្រក.កសក.នន ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូកែសម្រួលថ្មី និងឯកសារបន្ថែមក្នុងការនាំចូលសម្ភារៈកសិកម្ម ៤៥៣០

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១-៥-២០០៦ -លិខិតលេខ ១២៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហុង ណាម** ៤៥៤១

១១-៥-២០០៦ -លិខិតលេខ ១២៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេសេត** ៤៥៤៣

១១-៥-២០០៦ -លិខិតលេខ ១២៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យុង មីង ថុន** ៤៥៤៥

១១-៥-២០០៦ -លិខិតលេខ ១២៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផាឡាំងកាន (ខេមបូឌា)** ៤៥៤៧

១១-៥-២០០៦ -លិខិតលេខ ១២៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំ ធូបេកក្វ អិលធីឌី** ៤៥៥៩

| | | |
|---|---|---|
| ១១-៥-២០០៦ | -លិខិតលេខ១២៨៩ ពណ.នតកស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **ទេខហ្គាដ ឡូជីស្ទីក សឺវីស (ខេមបូឌា) ភីធីអ៊ី អិលធីឌី** " ប្រចាំរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា | ៤៥៥០ |
| ១៩-៥-២០០៦ | -លិខិតលេខ ១៣០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេក្រេដ អេលីហ្វិន អ៊ីមផត & អិចផត** | ៤៥៥១ |
| ១៩-៥-២០០៦ | -លិខិតលេខ ១៣០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្តារក្លាស ឌីវេឡុបមេន** | ៤៥៥៣ |
| ១៩-៥-២០០៦ | -លិខិតលេខ ១៣០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ុន ស៊ី ផាប់ប្លិក ខូ អិលធីឌី** | ៤៥៥៥ |
| ១៩-៥-២០០៦ | -លិខិតលេខ ១៣១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផ្លេនថេសិន អេហ្គ្រីខលឈើរល ឌីវេឡុបមេន (ខេមបូឌា) លីមីធីត** | ៤៥៥៧ |
| ១៩-៥-២០០៦ | -លិខិតលេខ ១៣១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ ស៊ី ឌី គ្រុប** | ៤៥៥៩ |

# ព្រះរាជក្រម

នស/រកម/០៦០៦/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងកិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ បានទាន់ពេលវេលាស្របតាមមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងកិច្ចព្រមព្រៀងអាស៊ានស្តីពីការ បំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងកិច្ចព្រមព្រៀងអាស៊ានស្តីពីការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដែលធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.២៣៩ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
ហត្ថលេខា
ម៉ុក ម៉ារ៉េត

លេខ: ៥៦៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជីនកេន**

asean

# កិច្ចព្រមព្រៀងអាស៊ាន

ស្តីពី

# ការបំពុលដោយផ្សែងអព្ភ័ ឆ្លងកាត់ព្រំដែន

ក្រសួងបរិស្ថាន

2003

# កិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលដោយផ្សែងអព្ទ ឆ្លងកាត់ព្រំដែន

ភាគីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ :

**សូមបញ្ជាក់ឡើងវិញថា** : ការប្តេជ្ញាចិត្តចំពោះបំណងប្រាថ្នារបស់សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ASEAN) ដូចដែលបានកំណត់នៅក្នុងសេចក្តីប្រកាសទីក្រុងបាងកកចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៦៧ ជាពិសេសដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីភាគអគ្នេយ៍ នៅក្នុងស្មារតី សមត្ថភាព និងភាពជាដៃគូរ និងតាមរយៈនេះដើម្បីចូលរួមចំណែកឆ្ពោះទៅរកសន្តិភាព វឌ្ឍនៈភាព និងវិបុលភាពនៅក្នុងតំបន់ ។

**សូមរំលឹកឡើងវិញថា** : កិច្ចព្រមព្រៀងទីក្រុងកូឡាឡាំពួរ ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលបានអនុម័តដោយបណ្តារដ្ឋមន្ត្រីបរិស្ថានអាស៊ាន នៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ១៩៩០ ដែលបានអំពាវនាវ ជាអាទិ៍គឺកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការទប់ស្កាត់ការបំពុលឆ្លងកាត់ព្រំដែន និងការប្រតិបត្តិប្រកបដោយប្រសិទ្ធិភាពខ្ពស់ក្នុងភាពចុះសំរុងគ្នា ។

**សូមរំលឹកឡើងវិញផងដែរថា** : ការអនុម័តនូវផែនការសហប្រតិបត្តិការ ASEAN ឆ្នាំ ១៩៩៥ ស្តីពី ការបំពុលឆ្លងកាត់ព្រំដែនដែលបានបញ្ជាក់យ៉ាងជាក់លាក់ ពីការបំពុលបរិយាកាសឆ្លងកាត់ព្រំដែន និងបានអំពាវនាវជាអាទិ៍គឺការបង្កើតនូវនិតិវិធី និងយន្តការសំរាប់កិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសជាសមាជិក ASEAN ក្នុងការទប់ស្កាត់ និងកាត់បន្ថយភ្លើងឆេះព្រៃនិងផ្សែងអព្ទ ។

**ដោយប្តេជ្ញាចិត្ត** : ដើម្បីផ្តល់ការប្រតិបត្តិចំពោះផែនការសកម្មភាពផ្សែងអព្ទក្នុងតំបន់ឆ្នាំ ១៩៩៧ និងផែនការសកម្មភាព ទីក្រុងហាណូយ ដែលអំពាវនាវអោយធ្វើការអនុវត្តអោយបានពេញលេញចំពោះផែនការសហប្រតិបត្តិការ ASEAN ឆ្នាំ ១៩៩៥ ស្តីពីការបំពុលឆ្លងកាត់ព្រំដែន ដោយសង្កត់ធ្ងន់ជាពិសេសលើផែនការសកម្មភាពផ្សែងអព្ទក្នុងតំបន់អោយសំរេចបាននៅឆ្នាំ ២០០១ ។

**ដោយទទួលស្គាល់ថា** : ជីវិតអាចនឹងទទួលរងឥទ្ធិពលមិនល្អ ដោយការបំពុលដោយផ្សែងអព្ទឆ្លងកាត់ព្រំដែន ។

**ដោយក្តីបារម្ភថា** : ការកើនឡើងនៃកំរិតបញ្ចេញសារធាតុបំពុលខ្យល់នៅក្នុងតំបន់ តាមការទាយទុកជាមុនថាអាចនឹងកើនឡើងនូវឥទ្ធិពលមិនល្អបន្ថែមទៀត ។

ដោយទទួលស្គាល់ថា : សេចក្តីត្រូវការដើម្បីធ្វើការសិក្សាពីមូលហេតុ និងទំនាក់ទំនងនៃការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន និងតំរូវការដើម្បីស្វែងរកដំណោះស្រាយសំរាប់បញ្ហាដែលបានកំណត់អត្តសញ្ញាណរួច ។

ស្នើបញ្ជាក់ថា : ឆន្ទៈរបស់បណ្តាប្រទេសជាសមាជិក ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត និងដើម្បីបង្កើតគោលនយោបាយថ្នាក់ជាតិសំរាប់ទប់ស្កាត់និងអង្កេតតាមដានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

ស្នើបញ្ជាក់ផងដែរថា : ឆន្ទៈរបស់បណ្តាប្រទេសជាសមាជិក ដើម្បីធ្វើការសំរបសំរួលសកម្មភាពថ្នាក់ជាតិសំរាប់ទប់ស្កាត់ និងអង្កេតតាមដានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន តាមរយៈការផ្លាស់ប្តូរនូវព័ត៌មានពិគ្រោះយោបល់ ស្រាវជ្រាវ និងអង្កេតតាមដាន ។

ដោយចំណងច្បាស់ថា : ដើម្បីទទួលធ្វើសកម្មភាពដាច់ពីគ្នា និងរួមគ្នា សំរាប់ធ្វើការវាយតំលៃនូវមូលហេតុដើមប្រភេទ និងវិសាលភាពនៃភ្លើងឆេះព្រៃ និង/រឺដីនិងផ្សែងអ័ព្ទតាមរយៈការអនុវត្តនូវគោលនយោបាយ ការប្រតិបត្តិបច្ចេកវិទ្យាបរិស្ថានប្រកបដោយសុវត្ថិភាព និងដើម្បីពង្រឹងសមត្ថភាពថ្នាក់ជាតិ តំបន់ និងកិច្ចសហប្រតិបត្តិការក្នុងការវាយតំលៃ ទប់ស្កាត់ កាត់បន្ថយ និងការគ្រប់គ្រងភ្លើងឆេះព្រៃ និង/រឺដី និងផ្សែងអ័ព្ទ ។

ដោយមានជំនឿថា : វិធានការដែលត្រូវការជាចំបាច់ ដើម្បីសំរេចបាននូវសកម្មភាពរួមគ្នានេះ គឺ សេចក្តីសំរេចនិងការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងនេះ ។

បានយល់ព្រមដូចតទៅ :

## ផ្នែកទី I បទប្បញ្ញត្តិទូទៅ

### មាត្រា ១
### ការប្រើប្រាស់ពាក្យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១ "ភាគីដែលជួយសង្គ្រោះ" មានន័យថា រដ្ឋ អង្គការអន្តរជាតិ អង្គភាពផ្សេងៗ រឺបុគ្គលដែលស្ម័គ្រចិត្តផ្តល់អោយ និង/រឺជួយដល់កិច្ចសង្គ្រោះទៅភាគីដែលស្នើ រឺទទួលនៅក្នុងព្រឹត្តការណ៍នៃភ្លើងឆេះព្រៃ និង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទ ។

២ "អាជ្ញាធរមានសមត្ថកិច្ច" មានន័យថា អង្គភាពមួយរឺច្រើន ដែលបានជ្រើសតាំង រឺផ្តល់អំណាចដោយភាគីនីមួយៗ ដើម្បីចូលរួមធ្វើសកម្មភាព តំណាងអោយប្រទេសនិមួយៗ ក្នុងការអនុវត្តន៍នូវកិច្ចព្រមព្រៀងនេះ ។

៣ "ការដុតដោយមានការត្រួតពិនិត្យ" មានន័យថា ការដុត ចំហេះ រឺឆ្លក់ភ្លើងទាំងឡាយដែលកើតមានឡើងក្នុងទីកន្លែងចំហរ ដែលត្រូវបានត្រួតពិនិត្យតាមរយៈច្បាប់ ការគ្រប់គ្រង បទបញ្ញត្តិ រឺគោលការណែនាំនានារបស់ថ្នាក់ជាតិ ហើយនិងមិនបណ្តាលអោយមានអគ្គីភ័យកើតឡើង និងការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

៤ "តំបន់ដែលងាយទទួលរងភ្លើងឆេះ" មានន័យថា តំបន់ដែលបានកំណត់ដោយអាជ្ញាធរជាតិ ជាតំបន់ដែលមានភ្លើងឆេះភាគច្រើន ងាយនិងទទួលរងគ្រោះថ្នាក់កើតមានឡើង ។

៥ "ស្ថាប័នទំនាក់ទំនង" មានន័យថា អង្គភាពដែលបានជ្រើសតាំង និងផ្តល់អំណាចដោយភាគីនីមួយៗដើម្បីទទួលនិងបញ្ជូនពត៌មាន និងទិន្នន័យដោយអនុលោមតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។

៦ "ការបំពុលដោយផ្សែងអ័ព្ទ" មានន័យថា ផ្សែងដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដីដែលបណ្តាលអោយជះឥទ្ធិពលដ៏ធ្ងន់ធ្ងរដល់សុខភាពមនុស្ស មានគ្រោះថ្នាក់ដល់ធនធានដែលមានជីវិត និងប្រព័ន្ធអេកូស៊ីស្តែម និងទ្រព្យសម្បត្តិ និងធ្វើអោយអន់ថយ រឺបង្អាក់ដល់ភាពសុខសាន្ត និងការប្រើប្រាស់ដ៏ត្រឹមត្រូវនូវបរិស្ថានធម្មជាតិ ។

៧ "ភ្លើងឆេះព្រៃ និង/រឺដី" មានន័យថា ការឆេះ ដូចជាឆេះស្រទាប់ធ្យូងថ្ម ការឆេះរុក្ខជាតិពុកផុយ (ដីមមោក) និងការឆេះចំការធំៗ ។

៨ "រដ្ឋជាសមាជិក" មានន័យថា រដ្ឋជាសមាជិក នៃសមាគមប្រជាជាតិអាស៊ីភាគអគ្នេយ៍ ។

៩ "ការដុតនៅទីចំហ" មានន័យថា ការដុត ចំហេះ រឺឆ្លក់ភ្លើងទាំងឡាយដែលកើតមានឡើងនៅក្នុងទីចំហ ។

១០ "ភាគី" មានន័យថា រដ្ឋជាសមាជិក ASEAN ដែលយល់ព្រមទទួលអនុវត្តនូវកាតព្វកិច្ចតាមរយៈកិច្ចព្រមព្រៀងនេះ ហើយដែលកិច្ចព្រមព្រៀងនេះចូលជាធរមានចំពោះតែភាគីជាសមាជិក ។

១១ "ភាគីដែលទទួល" មានន័យថា ភាគីដែលយល់ព្រមទទួលយកកិច្ចសង្គ្រោះដែលបានផ្តល់តាមរយៈ ភាគីជួយសង្គ្រោះ រឺភាគីផ្សេងទៀត នៅក្នុងព្រឹត្តិការណ៍នៃភ្លើងឆេះព្រៃ និង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទ ។

១២ "ភាគីដែលស្នើសុំ" មានន័យថា ភាគីដែលស្នើសុំពីភាគីផ្សេងទៀត រឺភាគីជួយសង្គ្រោះ នៅក្នុងព្រឹត្តិការណ៍នៃភ្លើងឆេះព្រៃ និង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទ។

១៣ "ការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន" មានន័យថា ការបំពុលដោយផ្សែងអ័ព្ទដែលលក្ខណៈរូបដើមនៃការបំពុលរបស់វាស្ថិតនៅទាំងមូល រឺជាផ្នែកមួយនៅក្នុងតំបន់ស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងថ្នាក់ជាតិនៃប្រទេសមួយ ហើយដែលផ្សែងអ័ព្ទទាំងនោះត្រូវបានរសាត់ចូលទៅក្នុងតំបន់ស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងនៃប្រទេសដទៃទៀត ។

១៤ "នយោបាយបញ្ឈប់ការដុត" (Zero burning policy) មានន័យថា នយោបាយដែលហាមឃាត់ការដុតនៅទីវាលចំហ ប៉ុន្តែអាចអនុញ្ញាតិអោយដុតដោយមានការត្រួតពិនិត្យក្នុងទំរង់មួយចំនួន ។

## មាត្រា ២

## កម្មវត្ថុ

កម្មវត្ថុនៃកិច្ចព្រមព្រៀងនេះគឺ ដើម្បីទប់ស្កាត់ និងអង្កេតតាមដានការបំពុលដោយផ្សែងអ័ព្ទ ដែលជាលទ្ធផលនៃភ្លើងឆេះព្រៃ និង/រឺដី ហើយត្រូវបានធ្វើការកាត់បន្ថយតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាថ្នាក់ជាតិ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ អោយកាន់តែខ្លាំងឡើងថែមទៀត ។ សកម្មភាពទាំងនេះអាចប្រព្រឹត្តទៅនៅក្នុងបរិបទរួមនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៣

## គោលការណ៍

ភាគីទាំងអស់ត្រូវបានណែនាំ តាមរយៈគោលការណ៍មួយចំនួនដូចខាងក្រោម ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ :

១ ដោយអនុលោមទៅតាម ធម្មនុញ្ញអង្គការសហប្រជាជាតិ និងគោលការណ៍នានានៃច្បាប់អន្តរជាតិ ដើម្បីធ្វើអាជីវកម្មលើធនធានរបស់ខ្លួនដែលមាន អោយស្របតាមគោលនយោបាយអភិវឌ្ឍន៍ និងបរិស្ថានរបស់ប្រទេសខ្លួន ហើយនិងការទទួលខុសត្រូវដោយធានាថា រាល់សកម្មភាពទាំងឡាយដែលស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន និងមិនបណ្តាលអោយមានការខូចខាតដល់បរិស្ថាន និងគ្រោះថ្នាក់ដល់

សុខភាពទៅបណ្តាប្រទេសដទៃទៀត រឺក៏ទៅក្រៅតំបន់កំណត់នៃដែនសមត្ថកិច្ចគ្រប់គ្រងថ្នាក់ជាតិ ។

២ នៅក្នុងស្មារតីសាមគ្គីភាព និងភាពជាដៃគូរ និងអនុលោមតាម តំរូវការ សមត្ថភាព និងស្ថានភាព របស់ប្រទេសនីមួយៗ ភាគីទាំងអស់ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការ និងសំរបសំរួលដើម្បីទប់ស្កាត់ និងអង្កេតតាមដាន ការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដី ហើយដែលគ្រោះថ្នាក់ទាំងនេះគួរតែត្រូវបានកាត់បន្ថយ ។

៣ ភាគីទាំងអស់ត្រូវចាត់វិធានការដោយប្រុងប្រយ័ត្នទុកជាមុន ដើម្បីទប់ស្កាត់ និងធ្វើការអង្កេតតាមដានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែនដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដី ហើយដែលត្រូវតែធ្វើការកាត់បន្ថយ និងខិតខំធ្វើអោយស្ថិតនៅក្នុងកំរិតអប្បបរិមាចំពោះឥទ្ធិពលដ៏អាក្រក់របស់វា ។ នៅទីកន្លែងណាមានការគំរាមកំហែងធ្ងន់ធ្ងរ រឺគ្រោះថ្នាក់ដែលពុំអាចកែប្រែបានពីការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ទោះបីគ្មានវិធីសាស្ត្រតាមបែបវិទ្យាសាស្ត្រក៏ដោយ វិធានការប្រុងប្រយ័ត្នទុកជាមុន គឺជាមធ្យោបាយដ៏ល្អបំផុត ដែលគ្រប់ភាគីជាប់ពាក់ព័ន្ធទាំងអស់ត្រូវតែទទួលយកទៅអនុវត្ត ។

៤ ភាគីទាំងអស់ត្រូវគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួន ដែលរួមមាន ធនធានព្រៃឈើ និងដីប្រកបដោយនិរន្តរភាពនៅក្នុងប្រព័ន្ធអេកូឡូស៊ី ។

៥ ក្នុងការដោះស្រាយការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ភាគីទាំងអស់ត្រូវធ្វើទំនាក់ទំនងអោយបានសមស្របជាមួយគ្រប់ភាគីជាប់ពាក់ព័ន្ធ រួមមានសហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល កសិករ និងសហគ្រាសឯកជន ។

## មាត្រា ៤
## ភារកិច្ចទូទៅ

ក្នុងការសំរេចអោយបាននូវគម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ ភាគីទាំងអស់ត្រូវ:

១ ធ្វើសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍ និងប្រតិបត្តិបណ្តាវិធានការនានា ដើម្បីទប់ស្កាត់និងអង្កេតតាមដានការបំពុលដោយ ផ្សែងអ័ព្ទឆ្លងកាត់ព្រំដែនដែលបណ្តាលមកពីភ្លើងឆេះព្រៃ និង/រឺដី ដែលអគ្គីភ័យទាំងនេះគួរត្រូវបានគេធ្វើការកាត់បន្ថយនិងធ្វើការត្រួតពិនិត្យប្រភពភ្លើងនេះ តាមរយៈការកំណត់អត្តសញ្ញាណនៃអគ្គីភ័យរួមមានការអភិវឌ្ឍន៍នូវគម្ពវិធីអង្កេតតាមដាន ការប៉ាន់ប្រមាណ និងប្រព័ន្ធផ្តល់ដំណឹងជាមុន ផ្លាស់ប្តូរព័ត៌មាននិងបច្ចេកវិទ្យា និងការផ្តល់កិច្ចសង្គ្រោះទៅវិញទៅមក ។

២ នៅពេលណាមានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែនចាប់ផ្តើមកើតចេញពី ក្នុងដែនដីរបស់ខ្លួនសាមុីប្រទេសត្រូវធ្វើការឆ្លើយតបអោយបានឆាប់រហ័សទៅនិងសេចក្តីស្នើសុំរបស់ប្រទេស រឺប្រទេសទាំងឡាយនូវពត៌មានដែលពាក់ពន្ធ័ រឺកិច្ចពិគ្រោះយោបល់នានា ដែលថាអគ្គីភ័យទាំងនោះ អាចជះឥទ្ធិពល តាមរយៈការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដោយឈរលើទស្សនៈដើម្បីធ្វើអោយនូវកំរិតទាបបំផុតនូវផលវិបាកទាំងឡាយនៃការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

៣ ចាត់វិធានការតាមបែបរដ្ឋបាល បញ្ញត្តិច្បាប់ និង/រឺវិធានការណ៍ដទៃទៀត ដើម្បីអនុវត្តន៍នូវកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ។

## ផ្នែកទី II ការឃ្លាំមើលតាមដាន វាយតំលៃ ទប់ស្កាត់ និងការឆ្លើយតប

### មាត្រា ៥

### មជ្ឈមណ្ឌលសំរបសំរួល ASEAN សំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន

១ មជ្ឈមណ្ឌលសំរបសំរួល ASEAN សំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដែលបន្ទាប់ពីពេលនេះតទៅហៅថា "មជ្ឈមណ្ឌល ASEAN ត្រូវបានបង្កើតឡើងតាមរយៈនេះ សំរាប់គោលបំណងបង្កលក្ខណៈងាយស្រួលដល់កិច្ចសហប្រតិបត្តិការ និងកិច្ចសំរបសំរួលចំណោមភាគីទាំងអស់ ក្នុងការគ្រប់គ្រងនូវផលប៉ះពាល់នៃភ្លើងឆេះព្រៃនិង/រឺដី ជាពិសេសការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនោះ ។

២ មជ្ឈមណ្ឌល ASEAN ត្រូវធ្វើកិច្ចការលើមូលដ្ឋានដែលថា ដំបូងបង្អស់អាជ្ញាធរជាតិ និងធ្វើសកម្មភាពដើម្បីពន្លត់អគ្គីភ័យ ។ នៅពេលណាអាជ្ញាធរថ្នាក់ជាតិធ្វើការប្រកាសអាសន្ន នោះគេអាចធ្វើការស្នើសុំទៅមជ្ឈមណ្ឌល ASEAN ដើម្បីជួយផ្តល់កិច្ចសង្គ្រោះ ។

៣ គណៈកម្មាធិការមួយដែលបានបង្កើតឡើងមានអ្នកតំណាង អាជ្ញាធរជាតិពីភាគីទាំងអស់និងត្រូវមើលការខុសត្រូវកិច្ចប្រតិបត្តិការនៃមជ្ឈមណ្ឌល ASEAN នេះ ។

៤ មជ្ឈមណ្ឌល ASEAN ត្រូវអនុវត្តន៍ទៅតាមមុខងារដូចបានចែងនៅក្នុងតារាងឧបសម្ព័ន្ធ និងមុខងារដ៏ទៃទៀត និងត្រូវកំណត់ដោយសន្និបាតរបស់ភាគីជាសមាជិក ។

## មាត្រា ៦

## អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នទំនាក់ទំនង

១ ភាគីនីមួយៗត្រូវជ្រើសតាំង អាជ្ញាធរមានសមត្ថកិច្ចមួយរឺច្រើន និងស្ថាប័នទំនាក់ទំនងមួយដែលត្រូវបាន ផ្តល់សិទ្ធអំណាច ដើម្បីធ្វើការងារទាំងនេះជំនួសមុខអោយប្រទេសរបស់ខ្លួន ទៅតាមតំរូវការនៃកិច្ចព្រម ព្រៀងនេះ ។

២ ភាគីនិមួយៗត្រូវជូនដំណឹងដល់ភាគីផ្សេងទៀត និងមជ្ឈមណ្ឌលអាស៊ានអំពី អាជ្ញាធរមានសមត្ថកិច្ច និង ស្ថាប័នទំនាក់ទំនងរបស់ខ្លួន និងបំលាស់ប្តូរផ្សេងៗ នៅក្នុងការជ្រើសតាំងរបស់ខ្លួន ។

៣ មជ្ឈមណ្ឌលអាស៊ាន ត្រូវផ្តល់យ៉ាងទៀងទាត់និងរួសរាន់ដល់ភាគីទាំងអស់ និងអង្គការអន្តរជាតិដែល ទាក់ទងនូវព័ត៌មាន ដូចបានចែងក្នុងកថាខ័ណ្ឌ២ ខាងលើ ។

## មាត្រា ៧

## ការអង្កេត តាមដាន

១ ភាគីនីមួយៗត្រូវចាត់វិធានការអោយបានសមស្របដើម្បីធ្វើការអង្កេតតាមដាននូវ :

ក-គ្រប់តំបន់ដែលងាយនិងទទួលរងភ្លើងឆេះ

ខ-រាល់ទីកន្លែងដែលមានភ្លើងឆេះព្រៃនិង/ដី

គ-រាល់ស្ថានភាពបរិស្ថានដែលនាំអោយមាននូវ ភ្លើងឆេះព្រៃ និង/រឺដី ទាំងនោះ និង

ឃ- ការបំពុលដោយផ្សែងអ័ព្ទ ដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដីទាំងនោះ ។

២ ភាគីនីមួយៗ ត្រូវជ្រើសតាំងអង្គភាពមួយរឺច្រើន ដើម្បីបំពេញមុខងារជាមជ្ឈមណ្ឌលធ្វើការអង្កេតតាម ដាន ថ្នាក់ជាតិ ដើម្បីទទួលរ៉ាប់រងធ្វើការអង្កេតតាមដានដូចបានចែងក្នុងកថាខ័ណ្ឌ១ខាងលើ ដោយអនុ លោមតាមទំរង់ការថ្នាក់ជាតិរៀងៗខ្លួន។

៣ ក្នុងព្រឹត្តការណ៍មានអគ្គីភ័យកើតឡើង ភាគីទាំងអស់ត្រូវចាប់ផ្តើមធ្វើសកម្មភាពជាបន្ទាន់ដើម្បីត្រួតពិនិត្យ រឺធ្វើការពន្លត់ភ្លើងទាំងនោះ ។

## មាត្រា ៨
## ការទាយតំលៃ

១ ភាគីនិមួយៗត្រូវធានាថា មជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិយល់ព្រមផ្តល់យ៉ាងទៀងទាត់ និងធ្វើការប្រាស្រ័យទាក់ទងដល់មជ្ឈមណ្ឌលអាស៊ានដោយផ្ទាល់ រឺតាមរយៈស្ថាប័នទំនាក់ទំនងរបស់ខ្លួន នូវទិន្នន័យដែលទទួលបានទាក់ទងទៅនឹងភ្លើងឆេះ តំបន់ដែលងាយទទួលរងគ្រោះភ្លើងឆេះព្រៃ និង/រឺដី រាល់ស្ថានភាពបរិស្ថានដែលនាំអោយមានភ្លើងឆេះព្រៃនិង/រឺដី និងការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដីទាំងនោះ ។

២ មជ្ឈមណ្ឌលអាស៊ានត្រូវទទួលធ្វើការប្រមូលផ្តុំនិងវិភាគ នូវទិន្នន័យដែលបានប្រាស្រ័យទាក់ទង តាមរយៈមជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិ រឺស្ថាប័នទំនាក់ទំនង ។

៣ លើមូលដ្ឋាននៃការវិភាគទិន្នន័យដែលទទួលបានទាំងនេះ មជ្ឈមណ្ឌលអាស៊ានត្រូវផ្តល់ជូនវិញទៅភាគីនិមួយៗតាមវិធីណាដែលអាចធ្វើបាន នូវការវាយតំលៃនៃភាពគ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាពមនុស្ស រឺបរិស្ថានដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដី និងដែលបណ្តាលអោយមានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

## មាត្រា ៩
## វិធានការទប់ស្កាត់

ភាគីនិមួយៗ ត្រូវទទួលយកនូវវិធានការដើម្បីទប់ស្កាត់ និងត្រួតពិនិត្យនូវសកម្មភាពទាំងអស់ដែលទាក់ទងនិងភ្លើងឆេះព្រៃនិង/រឺដី ដែលអគ្គិភ័យទាំងនេះអាចនាំដល់ការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន បណ្តាវិធានការទាំងនោះរួមមាន :

ក- ការអភិវឌ្ឍន៍ និងប្រតិបត្តិវិធានការច្បាប់ និងបទបញ្ញត្តិផ្សេងៗ មានដូចជាកម្មវិធី និងយុទ្ធសាស្ត្រនានាដើម្បីលើកកំពស់គោលនយោបាយបញ្ឈប់ការដុតនៅទីចំហ ដើម្បីដោះស្រាយភ្លើងឆេះព្រៃ និង/រឺដី ដែលបណ្តាលអោយមានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

ខ- ការអភិវឌ្ឍន៍គោលនយោបាយនានា អោយបានសមស្របដើម្បីធានាទប់ទល់នូវគ្រប់សកម្មភាពដែលអាចនាំទៅរកភ្លើងឆេះព្រៃនិង/រឺដី ។

គ- កំណត់អត្តសញ្ញាណនិងធ្វើការអង្កេតតាមដានតំបន់ដែលងាយទទួលរងភ្លើងឆេះ ដែលនាំអោយកើតមានឡើងនូវភ្លើងឆេះព្រៃនិង/រឺដី ។

ឃ- ពង្រឹងការគ្រប់គ្រងអគ្គីភ័យនៅមូលដ្ឋាន និងសមត្ថភាពប្រយុទ្ធប្រឆាំងអគ្គីភ័យ និងការសំរបសំរួល ដើម្បីទប់ស្កាត់ការកើតមានឡើងនូវភ្លើងឆេះព្រៃនិង/រឺដី ។

ង- លើកកំពស់ការអប់រំសាធារណៈ និងយុទ្ធនាការបង្កើតនូវចំណេះដឹង និងពង្រឹងការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងអគ្គីភ័យ ដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃនិង/រឺដី និងការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែនដែលកើតពីអគ្គីភ័យទាំងនោះ ។

ច- លើកកំពស់ និងប្រើប្រាស់នូវចំណេះ ដឹងនិងយកបទពិសោធន៍ដែលមានក្នុងការទប់ស្កាត់ និងការគ្រប់គ្រងអគ្គីភ័យនិង

ឆ- ធ្វើអោយប្រាកដថា រាល់វិធានការច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតត្រូវបានអនុវត្តដើម្បីត្រួតពិនិត្យការដុតនៅទីចំហ និងទប់ស្កាត់ការត្រួសត្រាយព្រៃដោយប្រើប្រាស់ភ្លើង ។

## មាត្រា ១០

## ការប្រុងប្រៀបទុកជាមុន

១- ភាគីទាំងអស់ត្រូវបង្កើតឡើងដោយរួមគ្នា រឺផ្ទាល់ខ្លួននូវយុទ្ធសាស្ត្រ និងផែនការទប់ទល់ ដើម្បីកំណត់គ្រប់គ្រង និងត្រួតពិនិត្យនូវភាពគ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាពមនុស្ស និងបរិស្ថានដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដី និងការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនោះ ។

២- ភាគីទាំងអស់ត្រូវរៀបចំអោយបានសមស្របនូវបែបបទសំរាប់ធ្វើប្រតិបត្តិការដែលមានលក្ខណៈជាខ្នាតគំរូរួម សំរាប់កិច្ចសហប្រតិបត្តិការតំបន់ និងសកម្មភាពថ្នាក់ជាតិដែលបានតំរូវក្រោមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១១

## ការឆ្លើយតបបន្ទាន់របស់ថ្នាក់ជាតិ

១- ភាគីនីមួយៗ ត្រូវធ្វើអោយប្រាកដថា រាល់វិធានការសមស្របផ្នែកច្បាប់ រដ្ឋបាល និងថវិកា ត្រូវបានគេអនុវត្ត ដោយធ្វើការប្រមូលផ្តុំនូវធនធានដែលមាន ដូចជា គ្រឿងបរិក្ខារ សំភារៈ ធនធានមនុស្ស

និងធនធានថវិកា ដែលត្រូវការចាំបាច់សំរាប់ឆ្លើយតប និងកាត់បន្ថយផលប៉ះពាល់ដោយភ្លើងឆេះព្រៃ និង/រឺដី និងការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនោះ ។

២- ភាគីនីមួយៗ ត្រូវជូនដំណឹងជាបន្ទាប់ទៅភាគីផ្សេងទៀតនិងមជ្ឈមណ្ឌលអាស៊ានទូវវិធានការទាំងនេះ ។

## មាត្រា ១២

## ការឆ្លើយតបបន្ទាន់រួមគ្នាតាមរយៈការផ្តល់ជំនួយសង្គ្រោះ

១- ប្រសិនបើភាគីណាមួយត្រូវការកិច្ចជួយសង្គ្រោះ នៅក្នុងព្រឹត្តការណ៍ភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យនៅក្នុងដែនដីរបស់ខ្លួននោះគេអាចធ្វើការស្នើសុំជំនួយសង្គ្រោះពីភាគីផ្សេងទៀត ដោយផ្ទាល់ រឺតាមរយៈមជ្ឈមណ្ឌលអាស៊ាន រឺប្រទេស រឺអង្គការអន្តរជាតិដទៃទៀត ។

២- កិច្ចការជួយសង្គ្រោះនេះអាចត្រូវបានអោយមកបំរើការនៅពេលមានសំណើយល់ព្រមពីភាគីដែលស្នើសុំ រឺក៏នៅពេលណាមានការផ្តល់ជូនដោយស្ម័គ្រចិត្តពីភាគីដទៃទៀតនោះក៏ត្រូវមានការយល់ព្រមពីភាគីម្ចាស់ផ្ទះផងដែរ ។

៣- ភាគីនីមួយៗ ត្រូវធ្វើការសំរេចចិត្ត និងជូនដំណឹងអោយបានឆាប់រហ័សដល់ភាគីដែលត្រូវស្នើសុំដោយផ្ទាល់ រឺតាមរយៈមជ្ឈមណ្ឌលអាស៊ាន ចំពោះសំណើសុំកិច្ចជួយសង្គ្រោះ អោយបានច្បាស់លាស់ ថាតើគេអាចផ្តល់នូវកិច្ចជួយសង្គ្រោះដែលបានស្នើបែបណា ពីទំហំ និងលក្ខខណ្ឌនៃការជួយសង្គ្រោះទាំងនោះ ។

៤- ភាគីនីមួយៗ ត្រូវធ្វើសេចក្តីសំរេចចិត្ត និងជូនដំណឹងអោយបានឆាប់រហ័សដល់ភាគីដែលជួយដោយផ្ទាល់ រឺតាមរយៈមជ្ឈមណ្ឌលអាស៊ាន ចំពោះការផ្តល់ជូន ការជួយសង្គ្រោះអោយបានច្បាស់លាស់ ថាតើគេអាចទទួលយកនូវជំនួយសង្គ្រោះដែលផ្តល់អោយឬទេ និងទំហំនិងលក្ខខ័ណ្ឌនៃការជួយសង្គ្រោះទាំងនោះ ។

៥- ភាគីដែលស្នើ ត្រូវបញ្ជាក់អោយបានច្បាស់នូវទំហំ និងប្រភេទនៃជំនួយសង្គ្រោះដែលត្រូវការ និងទីកន្លែងធ្វើសកម្មភាព និងត្រូវផ្តល់ជូនភាគីដែលត្រូវជួយ ដោយភ្ជាប់ជាមួយនិងពត៌មានដែលចាំបាច់ សំរាប់ធ្វើការកំណត់នូវវិសាលភាពដើម្បីអោយជំនួយសង្គ្រោះអាចឆ្លើយតបទៅនិងសេចក្តីស្នើសុំ ។ ក្នុងគ្រាដែលពុំអាចនិងធ្វើទៅបានរបស់ភាគីដែលស្នើសុំក្នុងការបញ្ជាក់អោយបានច្បាស់លាស់ពីទំហំ និងប្រភេទនៃជំនួយសង្គ្រោះដែលត្រូវការនោះភាគីដែលស្នើសុំ និងភាគីដែលជួយសង្គ្រោះត្រូវធ្វើការប៉ាន់ប្រមាណ និងសំរេចចិត្តរួមគ្នាទៅលើទំហំនិងប្រភេទជំនួយសង្គ្រោះដែលត្រូវការខាងលើ ។

៦- ភាគីទាំងអស់ត្រូវធ្វើការបញ្ជាក់ និងជំរាបជូនមជ្ឈមណ្ឌលអាស៊ាន នូវអ្នកជំនាញការគ្រឿងបរិក្ខារ សំភារៈ ដែលអាចរកបានក្នុងការិតសមត្ថភាពរបស់ខ្លួន សំរាប់ផ្តល់ជំនួយសង្គ្រោះទៅអោយភាគីផ្សេងឯទៀត ក្នុងគ្រាដែលមានភ្លើងឆេះព្រៃនិង/រឺដី រឺ ការបំពុលដោយផ្សែងអព្ទដែលអាចបណ្តាលមកពីអគ្គីភ័យ ក៏ដូចជាលក្ខខណ្ឌមួយចំនួនទៀត ជាពិសេសថវិកាអាចនិងផ្តល់ជូនក្រោមជំនួយសង្គ្រោះ ។

## មាត្រា ១៣
## ការចាត់ចែង និងត្រួតពិនិត្យជំនួយសង្គ្រោះ

លើកលែងតែមានការយល់ព្រមផ្សេងទៀត :

១- ភាគីដែលស្នើសុំ រឺទទួល ត្រូវធ្វើការហាត់ហ្វឹកហ្វឺន ពីការចាត់ចែង ត្រួតពិនិត្យ សំរបសំរួល និងការត្រួតត្រាមើលនូវជំនួយសង្គ្រោះនៅក្នុងដែនដីខ្លួន ។ នៅទីកន្លែងណាដែលជំនួយសង្គ្រោះមានជាប់ពាក់ពន្ធ័ដល់បុគ្គលិក ភាគីដែលជួយសង្គ្រោះ ដោយមានកិច្ចពិគ្រោះយោបល់ជាមួយភាគីដែលស្នើសុំ រឺទទួលត្រូវចាត់តាំងបុគ្គលិក រឺគ្រឿងបរិក្ខារដែលផ្តល់ដោយភាគីរបស់ខ្លួន ។ បុគ្គល រឺអង្គភាពដែលបានចាត់តាំងហើយត្រូវធ្វើការហាត់ហ្វឹកហ្វឺន ការត្រួតត្រាមើលដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីដែលស្នើសុំ រឺទទួល ។

២- ភាគីដែលស្នើសុំ រឺទទួល ត្រូវផ្តល់ជូននូវគ្រឿងបរិក្ខារ និងសេវាកម្មផ្សេងៗ ក្នុងស្រុកសំរាប់ចាត់ចែងការងារកិច្ចជួយសង្គ្រោះអោយបានល្អ និងមានប្រសិទ្ធិភាព ។ ហើយក៏ត្រូវធ្វើអោយប្រាកដជងដែរដល់កិច្ចការពារបុគ្គលិក គ្រឿងបរិក្ខារ និងសំភារៈផ្សេងៗ ដែលនាំចូលមកក្នុងទឹកដីរបស់ខ្លួនដោយ រឺក្នុងនាមនៃភាគីដែលជួយសង្គ្រោះ សំរាប់គោលបំណងទាំងនេះ ។

៣- ភាគីដែលផ្តល់ រឺទទួលជំនួយសង្គ្រោះ ដោយឆ្លើយតបទៅតាមសំណើដូចមានចែងក្នុងកថាខ័ណ្ឌ ១ ខាងលើ ត្រូវធ្វើការសំរបសំរួលអោយបានល្អប្រសើ ជំនួយសង្គ្រោះទាំងនោះនៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ១៤
## ករណីលើកលែង និងការជួយសំរួលចំពោះការផ្តល់ជំនួយសង្គ្រោះ

១- ភាគីដែលស្នើសុំ រឺទទួល ត្រូវអនុញ្ញាតិអោយបុគ្គលិករបស់ភាគីដែលជួយសង្គ្រោះ និងបុគ្គលិកដែលធ្វើកិច្ចការជំនួសមុខអោយភាគីខ្លួន នូវករណីលើកលែងនានាដែលចាំបាច់ និងការបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចរបស់ពួកគេ ។

២- ភាគីដែលស្នើសុំ រឺទទួលត្រូវអនុញ្ញាតិអោយភាគីដែលជួយសង្គ្រោះ នូវការអោយរួចពន្ធនានា រឺការបង់ថ្លៃផ្សេងៗទៀត លើគ្រឿងបរិក្ខារ និងសំភារៈដែលនាំចូលមកក្នុងដែនដីនៃប្រទេសដែលស្នើសុំ រឺទទួល សំរាប់គោលបំណងនៃការជួយសង្គ្រោះ ។

៣- ភាគីដែលស្នើសុំ រឺទទួល ត្រូវបង្កលក្ខណៈងាយស្រួលដល់ការចូលស្នាក់នៅ និងចេញពីដែនដីរបស់ខ្លួន ចំពោះបុគ្គលិក គ្រឿងបរិក្ខារ និងសំភារៈនានា ដែលពាក់ព័ន្ធ រឺប្រើប្រាស់នៅក្នុងការជួយសង្គ្រោះ ។

## មាត្រា ១៥

## ការឆ្លងកាត់នៃបុគ្គលិក គ្រឿងបរិក្ខារ និងសំភារៈនានា ចំពោះការផ្តល់ជំនួយសង្គ្រោះ

ផ្អែកតាមសំណើនៃភាគីដែលពាក់ព័ន្ធ ភាគីនិមួយៗត្រូវស្នើបង្កលក្ខណៈងាយស្រួលដល់ការឆ្លងកាត់តាមរយៈទឹកដីរបស់ខ្លួនដោយមានការជូនដំណឹងត្រឹមត្រូវនូវបុគ្គលិក គ្រឿងបរិក្ខារ និងសំភារៈនានាដែលពាក់ព័ន្ធ រឺប្រើប្រាស់នៅក្នុងការជួយសង្គ្រោះ ដល់ភាគីដែលស្នើសុំ រឺទទួល ។

## ផ្នែកទី III

## កិច្ចសហប្រតិបត្តិការ ផ្នែកបច្ចេកទេសនិងការស្រាវជ្រាវវិទ្យាសាស្ត្រ

## មាត្រា ១៦

## កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស

១- ដើម្បីបង្កើនការប្រុងប្រៀបទុកជាមុន និងកាត់បន្ថយភាពដែលអាចមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងបរិស្ថានដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះ ភាគីទាំងអស់ត្រូវទទួលធ្វើកិច្ចសហប្រតិបត្តិការ នៅក្នុងវិស័យនេះ រួមមានដូចតទៅ :

ក- សំរួលដល់ការប្រមូលផ្តុំនូវធនធានអោយបានសមស្របទាំងខាងក្នុង និងខាងក្រៅភាគីទាំងអស់ ។

ខ- លើកកំពស់ការធ្វើអោយមានគំរូខ្នាតឯកភាពគ្នានៃទំរង់របាយការណ៍ ទិន្នន័យ និងពត៌មាន ។

គ- លើកកំពស់ ការផ្លាស់ប្តូរ ពត៌មាន ជំនាញការ បច្ចេកវិទ្យា យុទ្ធវិធី និងមុខជំនាញដែលពាក់ព័ន្ធ ។

ឃ- ផ្តល់ រឺធ្វើការរៀបចំវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ មានការអប់រំនិងយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងជាពិសេស ទាក់ទងទៅនិងការជំរុញការអនុវត្តន៍វិធានការបញ្ឈប់ការដុត (Zero-burning) និងផលប៉ះពាល់នៃការបំពុលដោយផ្សែងអ័ព្ទ ទៅលើសុខភាពមនុស្សនិងបរិស្ថាន ។

ង- ធ្វើការអភិវឌ្ឍន៍ រឺបង្កើតឡើងនូវយុទ្ធវិធីស្តីពីការដុតដោយមានការត្រួតពិនិត្យជាពិសេស អ្នកធ្វើកសិកម្មពនេចរ និងម្ចាស់កសិដ្ឋានតូចៗ ដើម្បីធ្វើការផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍លើការអនុវត្តន៍ទាំងនោះ ។

ច- សំរបសំរួលដល់ការផ្លាស់ប្តូរបទពិសោធន៍ និងពត៌មានទាក់ទងក្នុងចំណោមអាជ្ញាធរអនុវត្ត នៃភាគីទាំងអស់ ។

ឆ- លើកកំពស់ និងធ្វើការអភិវឌ្ឍន៍ទីផ្សារ សំរាប់ការយកមកប្រើប្រាស់នូវជីវៈម៉ាស់ និងវិធីសាស្រ្តសមស្របសំរាប់ការចាក់ចោលនូវសំណល់កសិកម្ម ។

ជ- ធ្វើការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល ដល់ក្រុមអន្លត់អគ្គីភ័យ និងគ្រូបង្គោល ដើម្បីអោយពួកគេអាចធ្វើការបណ្តុះបណ្តាលនៅឯមូលដ្ឋាន កំរិតជាតិ កំរិតតំបន់ និង

ឈ- ពង្រឹង និងធ្វើអោយប្រសើរឡើងនូវសមត្ថភាពបច្ចេកទេសនៃភាគីទាំងអស់ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

២- មជ្ឈមណ្ឌលអាស៊ានត្រូវធ្វើការសំរបសំរួលសកម្មភាព សំរាប់កិច្ចសហប្រតិបត្តិការដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ ខាងលើ ។

## មាត្រា ១៧
## ការស្រាវជ្រាវវិទ្យាសាស្រ្ត

ភាគីទាំងអស់ត្រូវលើកកំពស់ និងគាំទ្រដោយរួមគ្នា រឺផ្ទាល់ខ្លួន នៅពេលណាដែលអាចធ្វើបាន រួមមាន កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ លើផ្នែកកម្មវិធីស្រាវជ្រាវ វិទ្យាសាស្រ្ត និងបច្ចេកទេស ដែលទាក់ទងដល់ឫសគល់ និងផលវិបាកទាំងឡាយនៃការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន និងមធ្យោបាយ វិធីសាស្រ្ត គ្រឿងបរិក្ខារ សំរាប់គ្រប់គ្រងភ្លើងឆេះព្រៃនិង/រឺដី រួមទាំងការពន្លត់អគ្គីភ័យ ។

# ផ្នែក IV ការរៀបចំស្ថាប័ន

## មាត្រា ១៨
## សន្និបាតភាគី

១- សន្និបាតភាគីត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងនេះ ។ សម័យប្រជុំដំបូងនៃសន្និបាតភាគី ត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋានមិនលើសពីរយៈពេល ១ឆ្នាំ ក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរ

មាន ។ បន្ទាប់មកសម័យប្រជុំសាមញ្ញនៃសន្និបាតភាគី និងត្រូវប្រារព្ធយ៉ាងតិច ១ ដងជារៀងរាល់ឆ្នាំ តាមតែអាចធ្វើទៅបាន ក្នុងពេលជាមួយគ្នា និងកិច្ចប្រជុំនានារបស់អាស៊ាន ។

២- សម័យប្រជុំវិសាមញ្ញ និងត្រូវប្រារព្ធឡើង នៅពេលវេលាផ្សេងទៀតពីខាងលើ នៅពេលមានសំណើពីភាគីមួយ ហើយដែលសំណើនោះត្រូវបានគាំទ្រដោយភាគីយ៉ាងតិចមួយផ្សេងទៀត ។

៣- សន្និបាតភាគីត្រូវ រក្សានូវការត្រួតពិនិត្យឡើងវិញបន្ត និងការវាយតំលៃនូវកិច្ចព្រមព្រៀងនេះ និងនៅទីបញ្ចប់ត្រូវ :

ក- ចាត់ទុកសកម្មភាពទាំងនេះជាការចាំបាច់ ដើម្បីធ្វើអោយប្រាកដនូវការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងនេះ ។

ខ- ពិនិត្យពិចារណាលើរបាយការណ៍នានា និងពត៌មានផ្សេងៗទៀត ដែលបានស្នើឡើងពីភាគីមួយ ដោយផ្ទាល់ រឺតាមរយៈលេខាធិការដ្ឋាន ។

គ- ពិនិត្យពិចារណា និងអនុមត័លើពិធីសារនានា ដោយអនុលោមតាមមាត្រា២១នៃកិច្ចព្រមព្រៀងនេះ។

ឃ- អនុមត័ ត្រួតពិនិត្យឡើងវិញ និងកែសំរួល តារាឧបសម្ព័ន្ធនានា ចំពោះកិច្ចព្រមព្រៀងនេះ ។

ង- បង្កើតឡើងនូវក្រុមការងារមួយចំនួនទៅតាមតំរូវការសំរាប់អនុវត្តកិច្ចព្រមព្រៀងនេះ និង

ច- ពិនិត្យពិចារណា និងទទួលយកនូវសកម្មភាពនានា បន្ថែមទៀតដែលតំរូវសំរាប់សំរេចអោយបាននូវកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១៩

## លេខាធិការដ្ឋាន

១- តាមរយៈនេះ លេខាធិការដ្ឋានមួយត្រូវបានបង្កើតឡើង

២- មុខងារនៃលេខាធិការដ្ឋាននេះត្រូវរួមបញ្ចូល

ក- រៀបចំចាត់ចែងដំណើរការកិច្ចប្រជុំសន្និបាតភាគី និងក្រុមការងារផ្សេងទៀត ដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងនេះ ។

ខ- បញ្ជូនទៅគ្រប់ភាគី នូវសេចក្តីជូនដំណឹង របាយការណ៍ និងពត៌មានផ្សេងៗទៀតដែលទទួលបានដោយ អនុលោមតាមកិច្ចព្រមព្រៀងនេះ ។

គ- ទទួលយកមកពិនិត្យនូវពត៌មាន និងការស៊ើបអង្កេតនានាពីភាគីទាំងអស់ និងធ្វើការពិគ្រោះយោបល់ជាមួយពួកគេ លើសំណើផ្សេងៗ ដែលទាក់ទងដល់កិច្ចព្រមព្រៀងនេះ ។

ឃ- ធ្វើអោយប្រាកដនូវការសំរបសំរួលដែលចាំបាច់ ជាមួយអង្គការអន្តរជាតិផ្សេងៗទៀតដែលពាក់ពន្ធ័ និងជាពិសេសការរៀបចំចាត់ចែងទៅតាមសេចក្តីត្រូវសំរាប់បំពេញកិច្ចការអោយមានប្រសិទ្ធិភាពដល់មុខងាររបស់លេខាធិការដ្ឋាន ។

ង- បំពេញការងារផ្សេងៗ ទៀតទៅតាមការផ្តល់អោយពីភាគីទាំងអស់ ។

៣- លេខាធិការដ្ឋានអាស៊ាន ត្រូវបំរើការងារ ជាលេខាធិការដ្ឋាននៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២០
## ការចាត់ចែងគ្រប់គ្រង មូលនិធិ

១- តាមរយៈនេះ មូលនិធិ សំរាប់អនុវត្តកិច្ចព្រមព្រៀងនេះត្រូវបានបង្កើតឡើង ។

២- មូលនិធិនេះ ត្រូវបានគេស្គាល់ថាជាមូលនិធិសំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

៣- មូលនិធិនេះ និងត្រូវចាត់ចែងគ្រប់គ្រងដោយលេខាធិការដ្ឋានអាស៊ាន ក្រោមការណែនាំពីសន្និបាតរបស់ភាគី ។

៤- ភាគីទាំងអស់ត្រូវបង់វិភាគទានដោយស្ម័គ្រចិត្តទៅមូលនិធិនេះ ដោយអនុលោមតាមសេចក្តីសំរេចនៃសន្និបាតភាគី ។

៥- មូលនិធិនេះ ត្រូវបានបើកចំហរចំពោះវិភាគទានដែលបានមកពីប្រភពផ្សេងៗទៀត ហើយដែលត្រូវទទួលការយល់ស្របរឺការយល់ព្រម ដោយភាគីទាំងអស់ ។

៦- ភាគីទាំងអស់អាចយកមកប្រើប្រាស់នូវធនធានបន្ថែមដែលត្រូវការ នៅទីន្លែងណាដែលចាំបាច់ សំរាប់អនុវត្តនូវកិច្ចព្រមព្រៀងនេះ ពីអង្គការអន្តរជាតិនានា ដែលពាក់ពន្ធ័ ជាពិសេសស្ថាប័នមូលនិធិក្នុងតំបន់ និងសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ ។

# ផ្នែក V នីតិវិធីទូទៅ

## មាត្រា ២១
## ពិធីសារនានា

១- ភាគីទាំងអស់ត្រូវធ្វើកិច្ចសហប្រតិបត្តិការនៅក្នុងការរៀបចំ និងការយល់ព្រមនូវពិធីសារនានាចំពោះ កិច្ចព្រមព្រៀងនេះ ដោយដាក់បញ្ញត្តិ វិធានការនានា ដែលបានព្រមព្រៀងគ្នា ដូចជា ទំរង់ការ និងបទដ្ឋានគំរូ សំរាប់អនុវត្តកិច្ចព្រមព្រៀងនេះ ។

២- សន្និបាតភាគីអាច ធ្វើការអនុម័តលើពិធីសារនានានៃកិច្ចព្រមព្រៀងនេះនៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំដោយមតិឯកភាពទូទៅនៃគ្រប់ភាគី ។

៣- អត្ថបទនៃពិធីសារដែលបានស្នើឡើងត្រូវបានគេធ្វើការ ទាក់ទងទៅគ្រប់ភាគីតាមរយៈលេខាធិការដ្ឋាន យ៉ាងតិច ៦ ខែមុនការប្រជុំ ។ សេចក្តីត្រូវការសំរាប់អោយពិធីសារចូលជាធរមានត្រូវបង្កើតឡើងតាមរយៈបញ្ញត្តិនៃពិធីសារនេះ ។

## មាត្រា ២២
## ការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀង

១- ភាគីទាំងឡាយអាចស្នើសុំវិសោធនកម្មចំពោះកិច្ចព្រមព្រៀងនេះបាន ។

២- អត្ថបទវិសោធនកម្មទាំងឡាយ ដែលបានស្នើសុំត្រូវបានគេធ្វើការទាក់ទងទៅគ្រប់ភាគីតាមរយៈលេខាធិការដ្ឋានយ៉ាងតិច ៦ ខែមុនការប្រជុំសន្និបាតភាគីដែលនៅឯសម័យប្រជុំនោះ ត្រូវបានគេស្នើសុំអោយធ្វើការអនុម័តលើសំណើវិសោធនកម្មទាំងនោះ ។ លេខាធិការដ្ឋាន ត្រូវធ្វើទំនាក់ទំនងផងដែរចំពោះភាគីចុះហត្ថលេខានៃកិច្ចព្រមព្រៀងលើសេចក្តីស្នើសុំវិសោធនកម្មនេះ ។

៣- វិសោធនកម្មទាំងឡាយនឹងត្រូវបានអនុម័ត ដោយមតិឯកភាពទូទៅ នៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំនៃសន្និបាតភាគី ។

៤- វិសោធនកម្មទាំងឡាយ ចំពោះកិច្ចព្រមព្រៀងនេះនឹងត្រូវបានដាក់អោយនៅក្រោមការទទួលស្គាល់ពីគ្រប់ភាគី ។ កន្លែងដាក់លិខិតសារ និងត្រូវចែកជូននូវវិសោធនកម្មដែលបានអនុម័តរួចទៅគ្រប់ភាគីសំរាប់សុំការ

ទទួលស្គាល់ ។ វិសោធនកម្មនេះ នឹងត្រូវចូលជាធរមានរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានបញ្ជូនដល់កន្លែងដំកល់ឯកសារ ហើយដែលបានទទួលស្គាល់ពីគ្រប់ភាគី ។

៥- ក្រោយពេលចូលជាធរមាននៃវិសោធនកម្ម ចំពោះកិច្ចព្រមព្រៀងនេះ ភាគីថ្មីផ្សេងទៀតនឹងត្រូវក្លាយជាភាគីមួយចំពោះ កិច្ចព្រមព្រៀងនេះដូចដែលបានធ្វើវិសោធនកម្មរួច ។

## មាត្រា ២៣

## ការអនុម័ត និងការធ្វើវិសោធនកម្ម ឧបសម្ព័ន្ធ

១- ឧបសម្ព័ន្ធនានាភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនេះ បង្កើតបានជាផ្នែកមួយដែលជាបតិដ្ឋាប័ន នៃកិច្ចព្រមព្រៀងនេះ និងដរាបណាពុំមានការបញ្ជាក់ផ្សេងទៀតទេនោះ ឯកសារយោងភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនោះរួបបញ្ចូលគ្នា ក្នុងពេលតែមួយ ទៅនឹងឯកសារយោង ឧបសម្ព័ន្ធដែលមាននោះ ។

២- ឧបសម្ព័ន្ធនានាត្រូវបានគេអនុម័ត ដោយមតិឯកភាពទូទៅ នៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំ នៃសន្និបាតភាគី ។

៣- ភាគីនានាអាចស្នើធ្វើវិសោធនកម្មទៅលើឧបសម្ព័ន្ធបាន ។

៤- វិសោធនកម្មទៅនឹងឧបសម្ព័ន្ធ ត្រូវបានគេអនុម័ត ដោយមតិឯកភាពទូទៅនៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំនៃសន្និបាតភាគី ។

៥- ឧបសម្ព័ន្ធភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនេះ និងវិសោធនកម្មទៅលើឧបសម្ព័ន្ធនានានឹងត្រូវដាក់អោយនៅក្រោមការទទួលស្គាល់ពីគ្រប់ភាគី ។ កន្លែងដំកល់ឯកសារ និងត្រូវចែកជូននូវឧបសម្ព័ន្ធ រឺវិសោធនកម្មទៅលើឧបសម្ព័ន្ធដែលបានអនុម័តរួចទៅគ្រប់ភាគី សំរាប់សុំការទទួលស្គាល់ ។ ឧបសម្ព័ន្ធរឺវិសោធនកម្មទៅលើឧបសម្ព័ន្ធត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីបានបញ្ជូនដល់កន្លែងដំកល់ឯកសារ ហើយដែលបានទទួលស្គាល់ពីគ្រប់ភាគី ។

### មាត្រា ២៤
### និតិវិធី និងបែបបទហិរញ្ញវត្ថុ

សម័យប្រជុំលើកដំបូងរបស់សន្និបាតភាគី ត្រូវអនុម័តដោយមតិឯកភាពទូទៅនូវ និតិវិធីរបស់ខ្លួន និង បែបបទហិរញ្ញវត្ថុ សំរាប់មូលនិធិអាស៊ាន ក្នុងការត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដើម្បី កំណត់ជាពិសេសការចូលរួមហិរញ្ញវត្ថុរបស់ភាគីទាំងអស់ទៅនឹងកិច្ចព្រមព្រៀងនេះ ។

### មាត្រា ២៥
### សេចក្តីរាយការណ៍

ភាគីទាំងអស់ត្រូវបញ្ជូនទៅលេខាធិការដ្ឋាននូវរបាយការណ៍ ស្តីពីការចាត់វិធានការនានាដើម្បីអនុវត្តកិច្ច ព្រមព្រៀងនេះក្នុងទំរង់ឯកភាពគ្នា និងរយៈពេលដូចដែលបានកំណត់ដោយសន្និបាតភាគី ។

### មាត្រា ២៦
### ទំនាក់ទំនងនៅនឹងកិច្ចព្រមព្រៀងដទៃទៀត

បទបញ្ញត្តិទាំងឡាយរបស់កិច្ចព្រមព្រៀងនេះ នឹងពុំធ្វើអោយប្រែប្រួលដល់សិទ្ធិ និងកាតព្វកិច្ចនានា របស់ ភាគីទាំងឡាយ ចំពោះសិទ្ធិសញ្ញា អនុសញ្ញា ឬកិច្ចព្រមព្រៀងដែលមានស្រាប់ដែលភាគីទាំងនោះជាសមាជិក ។

### មាត្រា ២៧

ជម្លោះនានារវាងភាគីទាំងអស់ ទៅតាមការបកស្រាយ ឬការអនុវត្តន៍ ឬការប្រតិបត្តិតាមកិច្ចព្រមព្រៀង ឬ ពិធីសារនានាដែលមាននោះត្រូវបានដោះស្រាយដោយការសម្រុះសម្រួលតាមរយៈកិច្ចពិគ្រោះយោបល់ ឬការចរចា គ្នា ។

## ផ្នែក VI អវសានបញ្ញត្តិ

### មាត្រា ២៨
### ការផ្តល់សច្ចានុម័ត ការទទួលស្គាល់ ការយល់ព្រម និងការចូលរួម

កិច្ចព្រមព្រៀងនេះនឹងត្រូវជាប្រធានបទសំរាប់ការផ្តល់សច្ចានុម័ត ការទទួលស្គាល់ ការយល់ព្រម ការចូលរួមដោយប្រទេសជាសមាជិក ។ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសំរាប់ការចូលរួមចាប់ពីថ្ងៃបន្ទាប់ពីកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខារួច ។ ឯកសារនៃការផ្តល់សច្ចានុម័ត ការទទួលស្គាល់ ការយល់ព្រម រឺការចូលរួម និងត្រូវដំកល់ទុកនៅទីកន្លែងដំកល់ឯកសារ ។

### មាត្រា ២៩
### ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានក្នុងរយៈពេល ៦០ថ្ងៃបន្ទាប់ពីការដាក់ឯកសារធ្វើសច្ចានុម័តការទទួលស្គាល់ ការយល់ព្រម និងការចូលរួមបានចំនួន ៦ច្បាប់ ។

២- សំរាប់ប្រទេសជាសមាជិកដែលផ្តល់សច្ចានុម័ត ទទួលស្គាល់ យល់ព្រម រឺចូលរួមទៅនឹងកិច្ចព្រមព្រៀងនេះ បន្ទាប់ពីការដាក់ឯកសារខាងលើបានចំនួន ៦ ច្បាប់ កិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមានក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីការដាក់ឯកសារពីប្រទេសជាសមាជិកទាំងនោះ ។

### មាត្រា ៣០
### ការបំរុងទុក

ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀតដោយកិច្ចព្រមព្រៀងនេះទេនោះ មិនមានការបំរុងទុកណាមួយដែលត្រូវបានធ្វើឡើងចំពោះកិច្ចព្រមព្រៀងនេះទេ ។

### មាត្រា ៣១
### ការិយាល័យទទួលឯកសារ

កិច្ចព្រមព្រៀងនេះនឹងត្រូវបានដំកល់ទុកនៅអគ្គលេខាធិការអាស៊ាន ហើយនឹងត្រូវផ្តល់អោយយ៉ាងរហ័សទៅប្រទេសនិមួយៗជាសមាជិកនូវឯកសារថតចំលងត្រឹមត្រូវទាំងនោះ ។

## មាត្រា ៣២
## អត្ថបទដើម

កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាភាសាអង់គ្លេស និងត្រូវចាត់ទុកថាជាអត្ថបទដើម ។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលបានទទួលការអនុញ្ញាតដោយត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០២ ។

ដោយរដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេ ដារុយសាឡែម

ឯកឧត្តម Dato Seri Paduka បណ្ឌិត Awang Haji Ahmadbin Haji Jumat
រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍

ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តម Keo Puth Reasmey
ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី

ដោយរាជរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

លោកជំទាវ Liana Bratasida
អនុរដ្ឋមន្ត្រី

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ឯកឧត្តម បណ្ឌិតសាស្ត្រាចារ្យ Bountiem Phissamay
រដ្ឋមន្ត្រីប្រចាំការិយាល័យនាយករដ្ឋមន្ត្រី
ប្រធានស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន

ដោយរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី

ឯកឧត្តម Dato Seri Law Hieng Ding
រដ្ឋមន្ត្រីក្រសួង វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន

ដោយរដ្ឋាភិបាលនៃសហភាព មីយ៉ាន់ម៉ា

ឯកឧត្តម U Thane Myint
លេខាធិការ គណៈកម្មាធិការជាតិផ្នែកបរិស្ថាន
អគ្គនាយកនៃក្រសួងការបរទេស

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន

ឯកឧត្តម Heherson T. Alvarez
លេខាធិការ នាយកដ្ឋានបរិស្ថាន និងធនធានធម្មជាតិ

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី

ឯកឧត្តម Lim Swee Say
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់

ឯកឧត្តម Chaisiri Anamarn
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រថៃឡង់ប្រចាំប្រទេសម៉ាឡេស៊ី

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ឯកឧត្តម Nguyen Van Dang
អនុរដ្ឋមន្ត្រី ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ឧបសម្ព័ន្ធ

## លក្ខខ័ណ្ឌយោងរបស់មជ្ឈមណ្ឌល សំរបសំរួលអាស៊ាន សំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអព្ទ័ឆ្លងកាត់ព្រំដែន

មជ្ឈមណ្ឌលអាស៊ានត្រូវ :

១- បង្កើត និងថែរក្សាការទាក់ទងជាប្រចាំ ជាមួយនិងមជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិនិមួយៗ ចំពោះទិន្នន័យដែលបានមកពីរូបភាពផ្កាយរណប និងការអង្កេតមើលដោយឧតុនិយម ដែលទាក់ទងទៅនឹង :
ក-ភ្លើងឆេះព្រៃនិង/រឺដី
ខ-លក្ខណ្ឌបរិស្ថានដែលនាំអោយមានអគ្គិភ័យទាំងនេះនិង
គ-គុណភាពខ្យល់ និងកំរិតនៃការបំពុលជាពិសេសផ្សែងអព្ទ័ដែលកើតចេញពីអគ្គិភ័យទាំងនេះ ។

២- ទទួល ពីមជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិនីមួយៗ រឺអង្គភាពទំនាក់ទំនងនូវទិន្នន័យខាងលើ ដោយធ្វើការបញ្ចូលគ្នា វិភាគ និងរៀបចំបញ្ចូលទិន្នន័យទាំងនេះ ទៅក្នុងទម្រង់ទ្រាយដែលមានលក្ខណៈងាយយល់ និងងាយប្រើប្រាស់ ។

៣- បង្កលក្ខណៈងាយស្រួលដល់កិច្ចសហការ និងការសំរបសំរួលក្នុងចំណោមភាគីទាំងអស់ដើម្បីបង្កើនការរៀបចំទុកជាមុនសំរាប់ឆ្លើយតបទៅនឹង ភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអព្ទ័ដែលកើតចេញពីអគ្គិភ័យទាំងនេះ ។

៤- បង្កលក្ខណៈងាយស្រួលដល់ការសំរបសំរួលក្នុងចំណោមភាគីទាំងអស់ រដ្ឋដទៃទៀតនិងអង្គការនានាដែលពាក់ព័ន្ធក្នុងការចាត់វិធានការដ៏មានប្រសិទ្ធិភាព ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអព្ទ័ដែលកើតចេញពីអគ្គិភ័យទាំងនេះ ។

៥- បង្កើត និងថែរក្សាបញ្ជីអ្នកឯកទេសដែលមកពីខាងក្រៅ និងខាងក្នុងតំបន់អាស៊ានដែលអ្នកទាំងនោះអាចធ្វើការងារបានក្នុងការចាត់វិធានការដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអព្ទ័ដែលកើតចេញពីអគ្គិភ័យទាំងនេះ និងរៀបចំបញ្ជីឈ្មោះដែលមាននេះអោយទៅភាគីទាំងអស់ ។

៦- បង្កើតអោយមាន និងថែរក្សាបញ្ជីឈ្មោះគ្រឿងបរិក្ខារ និងឧករណ៍បច្ចេកទេសដែលបានមកពីខាងក្រៅនិងក្នុងតំបន់អាស៊ាន ដែលគ្រឿងឧកបរណ៍ទាំងនេះអាចត្រូវបានគេប្រើក្នុងពេលចាត់វិធានការ ដើម្បីកាត់

បន្ថយនូវផលប៉ះពាល់ពីភ្លើងឆេះព្រៃនិង/រឺផ្សែង ការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះ និងរៀបចំបញ្ជីទាំងនេះអោយទៅភាគីទាំងអស់ ។

៧- បង្កើតអោយមាន និងថែរក្សាបញ្ជីឈ្មោះអ្នកឯកទេសដែលមកពីខាងក្រៅនិងក្នុងតំបន់អាស៊ាន សំរាប់គោលបំណងនៃការបណ្តុះបណ្តាល អប់រំ និងការធ្វើយុទ្ធនាការដើម្បីលើកកំពស់ការយល់ដឹង និងរៀបចំបញ្ជីឈ្មោះដែលមានអោយទៅភាគីទាំងអស់ ។

៨- បង្កើត និងថែរក្សា ការទំនាក់ទំនងជាមួយនិងប្រទេស និងអង្គការផ្តល់ជំនួយនានាសំរាប់យកមកប្រើប្រាស់ជាធនធានថវិកា និងធនធានផ្សេងទៀតដែលចាំបាច់ ដើម្បីទប់ស្កាត់ និងកាត់បន្ថយភ្លើងឆេះព្រៃនិង/រឺផ្សែង រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះ និងការរៀបចំទុកជាមុនរបស់ភាគីទាំងអស់ រួមទាំងសមត្ថភាពពន្លត់អគ្គិភ័យ

៩- បង្កើតនិងថែរក្សានូវបញ្ជីឈ្មោះអ្នកផ្តល់ជំនួយទាំងនេះ និងរៀបចំបញ្ជីឈ្មោះដែលមានទៅភាគីទាំងអស់ ។

១០- ឆ្លើយតបទៅនឹងសំណើសំរាប់ រឺផ្តល់ការជួយសង្គ្រោះទៅក្នុងគ្រាដែលមានភ្លើងឆេះព្រៃនិង/រឺផ្សែង រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះដោយ :

ក-ធ្វើការបញ្ជូនអោយបានឆាប់រហ័សនូវសំណើសំរាប់ជួយសង្គ្រោះទៅប្រទេសនិងអង្គការនានានិង

ខ-ធ្វើការសំរបសំរួល ជំនួយសង្គ្រោះទាំងនេះ ប្រសិនបើមានសំណើពីភាគីដែលស្នើសុំ រឺផ្តល់ដោយភាគីដែលជួយសង្គ្រោះ ។

១១- បង្កើតអោយមាន និងថែរក្សានូវប្រព័ន្ធបញ្ជូនពត៌មានសំរាប់ការផ្លាស់ប្តូរ ពត៌មានដែលទាក់ទងដូចជាអ្នកឯកទេស បច្ចេកវិទ្យា វិធីសាស្រ្ត និងមុខជំនាញវិជ្ជាជីវៈ និងរៀបចំប្រព័ន្ធដែលមាននេះ ក្នុងទំរង់ងាយស្រួល ផ្ញើរទៅគ្រប់ភាគីទាំងអស់ ។

១២- ចងក្រង និងផ្សព្វផ្សាយទៅភាគីទាំងអស់ នូវពត៌មានដែលពាក់ពន្ធ័ទៅនឹងបទពិសោធន៍ និងពត៌មានដែលមានសារៈប្រយោជន៍ផ្សេងទៀត ទាក់ទងនិងការប្រតិបត្តិនៃកិច្ចព្រមព្រៀងនេះ ។

១៣- ជួយដល់ភាគីទាំងអស់នៅក្នុងការរៀបចំនូវទំរង់ការគំរូបទដ្ឋានសំរាប់ប្រតិបត្តិការ ។

# ASEAN AGREEMENT ON TRANSBOUNDARY HAZE POLLUTION

The Parties to this Agreement,

REAFFIRMING the commitment to the aims and purposes of the Association of Southeast Asian Nations (ASEAN) as set forth in the Bangkok Declaration of 8 August 1967, in particular to promote regional co-operation in Southeast Asia in the spirit of equality and partnership and thereby contribute towards peace, progress and prosperity in the region,

RECALLING the Kuala Lumpur Accord on Environment and Development which was adopted by the ASEAN Ministers of Environment on 19 June 1990 which calls for, inter alia, efforts leading towards the harmonisation of transboundary pollution prevention and abatement practices,

RECALLING ALSO the adoption of the 1995 ASEAN Co-operation Plan on Transboundary Pollution, which specifically addressed transboundary atmospheric pollution and called for, inter alia, establishing procedures and mechanisms for co-operation among ASEAN Member States in the prevention and mitigation of land and/or forest fires and haze,

DETERMINED to give effect to the 1997 Regional Haze Action Plan and to the Hanoi Plan of Action which call for fully implementing the 1995 ASEAN Cooperation Plan on Transboundary Pollution, with particular emphasis on the Regional Haze Action Plan by the year 2001,

RECOGNISING the existence of possible adverse effects of transboundary haze pollution,

CONCERNED that a rise in the level of emissions of air pollutants within the region as forecast may increase such adverse effects,

CERTIFIED COPY SECRETARY GENERAL OF ASEAN

RECOGNISING the need to study the root causes and the implications of the transboundary haze pollution and the need to seek solutions for the problems identified,

AFFIRMING their willingness to further strengthen international co-operation to develop national policies for preventing and monitoring transboundary haze pollution,

AFFIRMING ALSO their willingness to co-ordinate national action for preventing and monitoring transboundary haze pollution through exchange of information, consultation, research and monitoring,

DESIRING to undertake individual and joint action to assess the origin, causes, nature and extent of land and/or forest fires and the resulting haze, to prevent and control the sources of such land and/or forest fires and the resulting haze by applying environmentally sound policies, practices and technologies and to strengthen national and regional capabilities and co-operation in assessment, prevention, mitigation and management of land and/or forest fires and the resulting haze,

CONVINCED that an essential means to achieve such collective action is the conclusion and effective implementation of an Agreement,

Have agreed as follows:

## PART I. GENERAL PROVISIONS

### Article 1
### Use of Terms

For the purposes of this Agreement:

1. "Assisting Party" means a State, international organisation, any other entity or person that offer and/or render assistance to a Requesting Party or a Receiving Party in the event of land and/or forest fires or haze pollution.

2. "Competent authorities" means one or more entities designated and authorised by each Party to act on its behalf in the implementation of this Agreement.

CERTIFIED COPY SECRETARY GENERAL OF ASEAN

3. "Controlled burning" means any fire, combustion or smouldering that occurs in the open air, which is controlled by national laws, rules, regulations or guidelines and does not cause fire outbreaks and transboundary haze pollution.

4. "Fire prone areas" means areas defined by the national authorities as areas where fires are most likely to occur or have a higher tendency to occur.

5. "Focal point" means an entity designated and authorised by each Party to receive and transmit communications and data pursuant to the provisions of this Agreement.

6. "Haze pollution" means smoke resulting from land and/or forest fire which causes deleterious effects of such a nature as to endanger human health, harm living resources and ecosystems and material property and impair or interfere with amenities and other legitimate uses of the environment.

7. "Land and/or forest fires" means fires such as coal seam fires, peat fires, and plantation fires.

8. "Member State" means a Member State of the Association of Southeast Asian Nations.

9. "Open burning" means any fire, combustion or smouldering that occurs in the open air.

10. "Party" means a Member State of ASEAN that has consented to be bound by this Agreement and for which the Agreement is in force.

11. "Receiving Party" means a Party that accepts assistance offered by an Assisting Party or Parties in the event of land and/or forest fires or haze pollution.

12. "Requesting Party" means a Party that requests from another Party or Parties assistance in the event of land and/or forest fires or haze pollution.

13. "Transboundary haze pollution" means haze pollution whose physical origin is situated wholly or in part within the area under the

CERTIFIED COPY SECRETARY GENERAL OF ASEAN

national jurisdiction of one Member State and which is transported into the area under the jurisdiction of another Member State.

14. "Zero burning policy" means a policy that prohibits open burning but may allow some forms of controlled burning.

## Article 2
## Objective

The objective of this Agreement is to prevent and monitor transboundary haze pollution as a result of land and/or forest fires which should be mitigated, through concerted national efforts and intensified regional and international co-operation. This should be pursued in the overall context of sustainable development and in accordance with the provisions of this Agreement.

## Article 3
## Principles

The Parties shall be guided by the following principles in the implementation of this Agreement:

1. The Parties have, in accordance with the Charter of the United Nations and the principles of international law, the sovereign right to exploit their own resources pursuant to their own environmental and developmental policies, and the responsibility to ensure that activities within their jurisdiction or control do not cause damage to the environment and harm to human health of other States or of areas beyond the limits of national jurisdiction.

2. The Parties shall, in the spirit of solidarity and partnership and in accordance with their respective needs, capabilities and situations, strengthen co-operation and co-ordination to prevent and monitor transboundary haze pollution as a result of land and/or forest fires which should be mitigated.

3. The Parties should take precautionary measures to anticipate, prevent and monitor tranboundary haze pollution as a result of land and/or forest fires which should be mitigated, to minimise its adverse effects. Where there are threats of serious or irreversible damage from transboundary haze pollution, even without

CERTIFIED COPY SECRETARY GENERAL OF ASEAN

scientific certainty, precautionary measures shall be taken by Parties concerned.

4. The Parties should manage and use their natural resources, including forest and land resources, in an ecologically sound and sustainable manner.

5. The Parties, in addressing transboundary haze pollution, should involve, as appropriate, all stakeholders, including local communities, non-governmental organisations, farmers and private enterprises.

## Article 4
## General Obligations

In pursuing the objective of this Agreement, the Parties shall:

1. Co-operate in developing and implementing measures to prevent and monitor transboundary haze pollution as a result of land and/or forest fires which should be mitigated, and to control sources of fires, including by the identification of fires, development of monitoring, assessment and early warning systems, exchange of information and technology, and the provision of mutual assistance.

2. When the transboundary haze pollution originates from within their territories, respond promptly to a request for relevant information or consultations sought by a State or States that are or may be affected by such transboundary haze pollution, with a view to minimising the consequences of the transboundary haze pollution.

3. Take legislative, administrative and/or other measures to implement their obligations under this Agreement.

CERTIFIED COPY
SECRETARY GENERAL OF ASEAN

## PART II. MONITORING, ASSESSMENT, PREVENTION AND RESPONSE

### Article 5
### ASEAN Co-ordinating Centre for Transboundary Haze Pollution Control

1. The ASEAN Co-ordinating Centre for Transboundary Haze Pollution Control, hereinafter referred to as "the ASEAN Centre", is hereby established for the purposes of facilitating co-operation and co-ordination among the Parties in managing the impact of land and/or forest fires in particular haze pollution arising from such fires.

2. The ASEAN Centre shall work on the basis that the national authority will act first to put out the fires. When the national authority declares an emergency situation, it may make a request to the ASEAN Centre to provide assistance.

3. A Committee composed of representatives of the national authorities of the Parties shall oversee the operation of the ASEAN Centre.

4. The ASEAN Centre shall carry out the functions as set out in Annex and any other functions as directed by the Conference of the Parties.

### Article 6
### Competent Authorities and Focal Points

1. Each Party shall designate one or more Competent Authorities and a Focal Point that shall be authorised to act on its behalf in the performance of the administrative functions required by this Agreement.

2. Each Party shall inform other Parties and the ASEAN Centre, of its Competent Authorities and Focal Point, and of any subsequent changes in their designations.

CERTIFIED COPY SECRETARY GENERAL OF ASEAN

3. The ASEAN Centre shall regularly and expeditiously provide to Parties and relevant international organisations the information referred to in paragraph 2 above.

## Article 7
## Monitoring

1. Each Party shall take appropriate measures to monitor:

   a. all fire prone areas,
   b. all land and/or forest fires,
   c. the environmental conditions conducive to such land and/or forest fires, and
   d. haze pollution arising from such land and/or forest fires.

2. Each Party shall designate one or more bodies to function as National Monitoring Centres, to undertake monitoring referred to in paragraph 1 above in accordance with their respective national procedures.

3. The Parties, in the event that there are fires, shall initiate immediate action to control or to put out the fires.

## Article 8
## Assessment

• បន្តផ្តល់អាទិភាព និង ជំរុញការរៀបចំថវិកាតាមកម្មវិធី និង ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបង្កើនប្រសិទ្ធភាពថវិកា និង ការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស ការដាក់អោយអនុវត្តសាកល្បងនូវការរៀបចំ និង អនុវត្តថវិកាតាមកម្មវិធីតាមរយៈការកែលំអកម្មវិធីសកម្មភាពជាអាទិភាព និង ការសាកល្បងអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម នៅក្រសួងចំនួន ៧ គឺ ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង ក្រសួងកិច្ចការនារី ។

• បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស ការកែលំអការអនុវត្តន៍ថវិកា តាមរយៈការកាត់បន្ថយនិតិវិធីចំណាយ ការពង្រឹងនិតិវិធី និង ធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និង ការកែលំអការរៀបចំថវិកា តាមរយៈការកែលំអវិធីសាស្ត្រនៃការរៀបចំថវិកា ព្រមទាំងការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដើម្បីសំរេចបានតាមគោលដៅជំហានទី១ គឺការបង្កើនភាពជឿទុកចិត្តបាននៃថវិកា និង ការចាប់ផ្តើមជំហានទី២ គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ តាមរយៈការដាក់អោយអនុវត្តនូវប្លង់គណនេយ្យ និង មាតិកាថវិកាថ្មី នៅក្នុងក្របខ័ណ្ឌកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

**ខ- គំរោងចំណូលថវិកា**

១៣- ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃគំរោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការអនុវត្តន៍អោយបានសំរេចទៅតាមផែនការសកម្មភាព និង គោលដៅនៃស្ទួចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសំរេចអោយបាននូវកំរិតចំណូលក្នុងស្រុកសរុបប្រមាណ ១១,៩៥% នៃផសស គឺមានកំណើន ១,៦% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសំរេចអោយបាន ៨,៨% នៃផសស គឺមានកំណើន ០,៩% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ចំណូលមិនមែនសារពើពន្ធត្រូវសំរេចអោយបាន ២,៦៣% នៃផសស គឺមានកំណើន ០,៤% ធៀបនឹងឆ្នាំ ២០០៦ និង ចំណូលមូលធនក្នុងស្រុកត្រូវសំរេច

អោយបាន ០,៥៣% នៃផសស គឺមានកំណើន ០,២៨% ធៀបនឹងឆ្នាំ ២០០៦ (៨៥ ពាន់លានរៀល បានមកពីធនាគារជាតិ លើការផ្ទេរបំណុលដែលបានលើកលែងដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ) ។

១៤- ដើម្បីសំរេចបានតាមគោលដៅនៃការប្រមូលចំណូលសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តអនុវត្តបណ្តាវិធានការហ្មឹងម៉ាត់ទាំងឡាយ នៅក្នុងកម្មវិធីសកម្មភាពកែទំរង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតទៅលើបណ្តាវិធានការសំខាន់ៗមួយចំនួនដូចខាងក្រោម ÷

**ទី១- ផ្នែកចំណូលពន្ធដារ:**

- បន្តការពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ ការធ្វើសវនកម្មពន្ធ ការពង្រីកមូលដ្ឋានយកពន្ធ ការបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និង ការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។
- បន្តអនុវត្តនូវកម្មវិធីកែលំអរចនាសម្ព័ន្ធ តាមរយៈការអនុវត្តន៍នូវប្រព័ន្ធគ្រប់គ្រងតាមបែបអន្តរជាតិចំពោះរាល់តួនាទី ភារកិច្ច និង ប្រតិបត្តិការរបស់នាយកដ្ឋានពន្ធដារ ។
- កសាង និង អនុវត្ត នូវផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាពត៌មាន ជាពិសេសខាងផ្នែកប្រមូលពន្ធ ការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។
- អនុវត្តទាំងស្រុង និង ឱ្យបានហ្មឹងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។
- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីករបបពិតនៅតាមបណ្តាខេត្ត- ក្រុងផ្សេងទៀត និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។
- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និង មធ្យម ។
- ពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេងកាត ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលជាអតិបរិមាពីវិស័យនេះ តាមរយៈការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ។
- ធ្វើការសិក្សាអំពីវិចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។
- បន្តពង្រឹងអភិបាលកិច្ចរបស់នាយកដ្ឋានពន្ធដារ ។

**ទី២- ផ្នែកចំណូលពន្ធគយ:**

- បន្តជំរុញការអនុម័តច្បាប់គយ និង ត្រៀមរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ ។
- បន្តកែលំអនិតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ- ចូល និង ក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។
- ចាប់ផ្តើមអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់ទីចាត់ការគយ និង រដ្ឋាករ ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

*ក.* វិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកង-យោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល និង អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើ រត់ពន្ធត្រូវតែបង្ហាញឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត នូវឋវភាពនៃការងាររបស់ខ្លួនក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេស លើវិធានការកែលំអផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេទយិកភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារអេឡិចត្រូនិច និង ការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ.* សហការជាមួយនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរព័ត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។

*គ.* លើកឡើង និង អនុវត្តនូវវិធានការច្បាស់លាស់ តែទន់ភ្លន់ លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះ-បណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តការពង្រឹង និង កែលំអរដ្ឋបាលគយ តាមរយៈការធ្វើស្វ័យប្រវត្តិកម្មនីតិវិធីគយ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជនពិសេសគឺត្រូវរៀបចំឱ្យបានសម្រេច ហើយដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធបញ្ជរតែមួយ (Single Window) សម្រាប់ត្រួតពិនិត្យការនាំចេញ និង នាំចូល នៅតាមច្រកព្រំដែនមួយចំនួន ពិសេស ត្រូវចាប់ផ្តើមនៅកំពង់ផែក្រុងព្រះសីហនុ ។

- ពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និង ការប្រមូលចំណូល ។

- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និង រដ្ឋាករ ។

**ទី៣- ចំណូលមិនមែនសារពើពន្ធ:**

- អនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រី លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការ-ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធចំណូលមិនមែនសារពើពន្ធ ហើយដាក់ចេញនូវផែនការសកម្មភាពជាក់លាក់ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរណ៍ស៊ីវិលចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញការរៀបចំបទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធឱ្យបានរួចរាល់ និង ការរៀបចំអនុក្រឹត្យដែលពាក់ព័ន្ធ ដើម្បីអនុវត្តបទបញ្ជានេះឱ្យមានប្រសិទ្ធភាព ។

- បញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ លើកលែងតែសារពើភ័ណ្ឌដីរដ្ឋ ដែលត្រូវបន្តអនុវត្តនៅក្នុងរយៈពេលវែងខាងមុខ ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

១៥- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៧ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ជាមួយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៦ នេះតទៅ រហូតដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៦ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះហើយផ្ញើជូនគណៈរដ្ឋមន្ត្រីអោយបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ ២០០៦ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ហើយផ្ញើជូនរដ្ឋសភាអោយបានក្នុងសប្តាហ៍ទី១ នៃខែ វិច្ឆិកា ២០០៦ ដើម្បីស្ថាប័ននីតិបញ្ញត្តិមានពេលគ្រប់គ្រាន់ ក្នុងការពិនិត្យ ពិភាក្សា និង អនុម័តសេចក្តីព្រាងច្បាប់នេះអោយបានមុនថ្ងៃ ២៥ ខែ ធ្នូ ២០០៦ ។

**គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧**

១៦- បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងតែប្រឈមមុខនឹងបញ្ហាមួយចំនួន នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូលដើម្បីសងបំណុលចាស់ផង និង ដើម្បីបំពេញតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ផង ។ បញ្ហាប្រឈមទាំងអស់នោះ រួមមានដូចខាងក្រោម ÷

*ទី១-* ការធានាអោយបាននូវការគោរពវិន័យថវិកាយ៉ាងខ្ជាប់ខ្ជួន តាមរយៈការពង្រឹងការរៀបចំថវិកាអោយបានគ្រប់ជ្រុងជ្រោយ និង សុក្រឹត ដើម្បីកាត់បន្ថយជាអតិបរិមានូវចំណាយមិនបានគ្រោងទុក និង សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និង ចំណាយដែលមិនចាំបាច់ ដើម្បី សម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយប្រសិទ្ធភាព និង ប្រកបដោយភាពជឿទុកចិត្តបាន ។

*ទី២-* ការរៀបចំកម្មវិធីចំណូល-ចំណាយអោយបានសុក្រឹត និង ការអនុវត្តន៍អោយបានហ្មឹងម៉ាត់ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីកាត់បន្ថយបំណុលសាច់ប្រាក់កកស្ទះនៅរតនាគារ ក្នុងគោលដៅបង្កើនភាពជឿទុកចិត្តបាននៃការអនុវត្តន៍ថវិកា ។ លើសពីនេះ ការបង្កើនការគោរពយ៉ាងហ្មឹងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសចៀសវាងនូវការផ្ទេរ

ឥណទានថវិកាដែលនៅសល់ទៅឆ្នាំបន្ទាប់ ព្រមទាំងការចេញអាណត្តិបម្រុងទុក និង ការចេញអាណត្តិច្រើន ហួសទៅបង្គរនៅធនាគារជាតិ ដែលជាប្រការធ្វើឱ្យកើតមានឡើងនូវបំណុលសាច់ប្រាក់ថ្មីទៀត ។

*ទី៣-* បន្តពង្រឹងការគ្រប់គ្រងបំណុល ជាពិសេស ការកសាងទិន្នន័យ និង ការរៀបចំកម្មវិធីសង បំណុលអោយបានច្បាស់លាស់ និង ដោយផ្សាភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និង ការបន្តអនុវត្ត យ៉ាងហ្មឺងម៉ាត់នូវការខិតខំឥណទានដែលបំពីអោយគោលនយោបាយអាទិភាព ។

*ទី៤-* បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ជាពិសេសចំពោះបណ្តាវិស័យអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មាន ផ្លូវ- ថ្នល់ ស្ពាន និង ប្រព័ន្ធស្រោចស្រព ដែលជាអាទិភាពខ្ពស់ផុតរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ៣ នៃរដ្ឋសភា ។

## III- និតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៧

### ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០០៧

១៧- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តា លក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវរៀបចំ គម្រោងចំណូលថវិការបស់ខ្លួនដូចតទៅៈ

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រា មូលដ្ឋានប្រមូលពន្ធ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និង កែលំអរដ្ឋបាល និង គោលនយោបាយពន្ធដារ គយ និង រដ្ឋាករ និង ការធ្វើវិចារណៈកម្មសារពើពន្ធ ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ច សន្យាជួលសេវាកម្ម និង ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាដើម ។ល។

ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិដែលសំរេចបាននៅក្នុងឆ្នាំកន្លងមក និងការ- អភិវឌ្ឍន៍សេដ្ឋកិច្ច ។ គ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ទាំងអស់ ត្រូវរៀបចំគំរោងចំណូលនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយបានត្រឹមថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំកិច្ចប្រជុំពិភាក្សាលើគំរោងចំណូលនេះជាមួយគ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត- ក្រុង និង ធ្វើការបូកសរុបអោយបានចប់សព្វគ្រប់មុនការចាប់ផ្តើមចរចាថវិកានៅក្នុងខែសីហា ។

**ខ- ការគ្រោងចំណាយថវិកាឆ្នាំ ២០០៧**

១៨- ការរៀបចំគំរោងឥណទានចំណាយថវិកាត្រូវធ្វើឡើងជាពីរដំណាក់កាលគឺ ដំណាក់កាលទី ១ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដែលរួមមានការបញ្ជាក់ពី ទស្សនៈវិស័យ និង គោលបំណង ព្រមទាំងយុទ្ធសាស្ត្រ និង គោលដៅរយៈពេលមធ្យម (២០០៧-២០០៩) ដើម្បីបំរើអោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ដើម្បីបំរើអោយគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងកម្មវិធីសកម្មភាពចាំបាច់ដែលត្រូវអនុវត្តជាមួយនឹងតំរូវការថវិកាតាមប្រភេទ ។ ដំណាក់កាលទី ២ ត្រូវរៀបចំគណនាតំរូវការថវិកាដោយលំអិតទៅតាម ជំពូក គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើ តំរូវការជាក់ស្តែង និង ដោយផ្ទាល់ សំរាប់បំរើអោយការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ដែលត្រូវបានកំណត់ នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាឥណទានចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹង មុខសញ្ញាចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈនៃការផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយដែលបានកំណត់កន្លងមក ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយ របស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សា សំរាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តំរូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និង មានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាមជំពូក គណនី និង អនុគណនី នីមួយៗ ។

**គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៧**

១៩- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការណ៍ចំណាយទៅតាមប្រភេទ និង ជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយសារពើពន្ធ និង ថវិកា សំរាប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ធ្វើជាមូលដ្ឋានក្នុងការរៀបចំគំរោងចំណាយលំអិតទៅតាម គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ដើម្បីបំរើអោយតំរូវការជាក់ស្តែងក្នុងការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃត្រីមាសទី ១ ឆ្នាំ ២០០៧ នេះ នឹងមិនមានការអនុញ្ញាតិឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ នៅតាមខេត្ត-ក្រុងទេ ។

២០- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និង បណ្តាវិធានការដូចខាងក្រោមៈ

ក- ចំណាយបៀវត្ស ត្រូវគ្រោងដោយបង្កើន ១៥% លើបៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៦ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និង តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការ តម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មិនត្រូវគិតអតិថិជនណានៅក្នុងចំណាយបៀវត្សនេះទេ ។ ចំពោះបុគ្គលិកអណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។

**ខ-** ចំណាយដំណើរការរដ្ឋបាល ទិញសំភារៈ និង ការជួសជុលតូច ត្រូវគ្រោងដោយកាត់បន្ថយជារួម ៥% គឺត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និង សន្សំសំចៃបំផុត ជាពិសេស ចំពោះសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនអោយមានចំណាយលើសពីឥណទានថវិកា ដែលបានគ្រោងសំរាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬ សេវាមកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។ កន្លងមកចំណាយសម្រាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវមានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសម្រាប់មុខសញ្ញាទាំងនេះ ចេះតែកើនឡើង ហើយការទូទាត់មិនបានទាន់ពេលវេលា ដែលនាំអោយមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយ អគ្គិសនី ទូរស័ព្ទ និង ទឹក ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និង ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក អោយបានត្រឹមត្រូវ ម៉ត់ចត់ និង ប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្លុចរន្តអគ្គិសនី ទូរស័ព្ទ និង ទឹក ប្រើប្រាស់ផ្ទាល់ខ្លួនខុសមុខសញ្ញា របស់ក្រសួង ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និង ចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសំរាប់អគ្គិសនី ទូរស័ព្ទ និង ទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុនធ្វើជាពិដាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះអោយចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ពិតប្រាកដរបស់ក្រសួងស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក័យប័ត្រប្រចាំខែនីមួយៗ អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក័យប័ត្រ និង រៀបចំទូទាត់អោយបានទៀងទាត់ និង ទាន់ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនអោយមានការពន្យាការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រង ការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ហើយដាក់ឱ្យគ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និង ហ្មឹងម៉ាត់បំផុត ។

- ក្នុងខណៈដែលប្រេងឥន្ធនៈកំពុងឡើងថ្លៃ គំរោងចំណាយប្រេងឥន្ធនៈសំរាប់ឆ្នាំ ២០០៧ ត្រូវកាត់បន្ថយចំនួន ៥% ធៀបនឹងឥណទានសំរាប់ចំណាយប្រេងឥន្ធនៈក្នុងឆ្នាំ ២០០៦ ដើម្បីអនុវត្តវិធានការសន្សំសំចៃថាមពលថ្នាក់ជាតិផង និង ដើម្បីត្រៀមបង្វែរចំណាយនេះ សំរាប់ចំណាយជាយថាហេតុនៃគ្រោះធម្មជាតិផង ។

គ- ចំពោះចំណាយសំរាប់ជំពូក គណនី និង អនុគណនីផ្សេងៗទៀត ត្រូវគ្រោងទៅតាមតំរូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ក្នុងករណីតំរូវអោយមានកំណើន ដោយមានការវិភាគ និង ពន្យល់ច្បាស់លាស់ ក៏កំណើននោះមិនត្រូវអោយលើសពី ៥% នៃកញ្ចប់ថវិកាដែលបានអនុម័តឆ្នាំ ២០០៦ ដែរ ។ ចំពោះ ក្រសួងទាំង ៧ ដែលត្រូវចាប់ផ្តើមអនុវត្តសាកល្បងនូវថវិកាតាមកម្មវិធី ត្រូវញែកគំរោងចំណាយជាពីរផ្នែកសំរាប់ថវិកាតាមកម្មវិធី និង ថវិកាតាមមាតិកាទៅតាមគ្រប់ជំពូក គណនី និង អនុគណនី នីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំង ៧ នេះ មកការពារគំរោងថវិកាតាមកម្មវិធីនេះដោយឡែក ។

ឃ- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គំរោងចំណូល និង គំរោងចំណាយថវិកា ដែលក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាមូលដ្ឋានសំរាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬ មន្ទីរជំនាញខេត្ត- ក្រុង ដែលមិនបានបំពេញ និង ផ្តល់ពត៌មានគ្រប់គ្រាន់សំរាប់ការប្រជុំការពារថវិកាទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវជូនពត៌មានទៅអង្គភាពអោយបានទាន់ពេលវេលា ដើម្បីបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានសិទ្ធិយកមូលដ្ឋាននៃថវិកាឆ្នាំ ២០០៦ ហើយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូក គណនី និង អនុគណនីខាងលើ ដើម្បីកំណត់គំរោងថវិការបស់អង្គភាពនោះ ដើម្បីជាមូលដ្ឋានសំរាប់ការប្រជុំការពារថវិកា និង រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអោយបានទាន់ពេលវេលា ។

## ឃ- ការរៀបចំ និង ការវិភាគសំណើនានា

២១- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ ២០០៦ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៥ /០៤០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០៧ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន ។ ក្រសួង- ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និង ការណែនាំទាំងឡាយខាងលើនេះសម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា:

- ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង- ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត- ក្រុងមានការប្រែប្រួល ។
- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ។

• ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ ល ។

២២- គម្រោងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែម ត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៣- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៤- បច្ចេកទេសវិភាគដ៏ទៃទៀតគឺ យកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងនីមួយៗ ត្រូវតែបំពេញទៅលើៈ

- ទិសដៅរបស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងនីមួយៗ
- បណ្តាសកម្មភាពជាអាទិភាពរបស់ខ្លួនដែលបានកំណត់ច្បាស់លាស់
- កម្មវិធីដែលត្រូវចាប់ផ្តើមអនុវត្ត
- មធ្យោបាយដំណើរការ និង
- វិធានការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

## IV- សេចក្តីសន្និដ្ឋាន

២៥- រាជរដ្ឋាភិបាលមានឆន្ទៈដាច់ខាតក្នុងការបន្តនូវកំណែទម្រង់គ្រប់វិស័យ ពិសេសគឺការពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតម្រូវឱ្យគ្រប់ក្រសួងស្ថាប័នទាំងអស់ អនុវត្តយ៉ាងហ្មឹងម៉ាត់ និង ម៉ត់ចត់បំផុត នូវបទបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង ប្រកាសស្តីពីការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ។ ដើម្បីធានាឱ្យបាននូវភាពស័ក្តសិទ្ធិ និង ប្រសិទ្ធភាពក្នុងការអនុវត្តន៍

ចំណាយថវិកាជាតិ ជាពិសេស ដើម្បីជៀសវាងបញ្ហាកកស្ទះសាច់ប្រាក់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបន្តសហការជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំឱ្យបានត្រឹមត្រូវនូវផែនការលទ្ធកម្ម និង កម្មវិធីដេញថ្លៃជាសាធារណៈ និង ផែនការតម្រូវការសាច់ប្រាក់របស់ក្រសួង-ស្ថាប័ននីមួយៗ ដោយផ្អែកលើកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សំរាប់ធានាទូទាត់កិច្ចសន្យាទាំងអស់នេះជាដំណាក់ៗ នៅក្នុងឆ្នាំថវិកានីមួយៗ ។

**២៦-** ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់នូវផែនការយុទ្ធសាស្ត្រថវិកា និង គំរោងចំណូល-ចំណាយថវិការបស់ខ្លួន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៦ ចំពោះគំរោងចំណូល ហើយត្រឹមថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៦ ចំពោះគំរាងចំណាយ ពីព្រោះការពិភាក្សាគំរោងចំណូលនឹងត្រូវធ្វើអោយបានមុនការពិភាក្សាគំរោងចំណាយដែលនឹងត្រូវចាប់ផ្តើមនៅថ្ងៃទី ០១ ដល់ ៣១ ខែសីហា ឆ្នាំ ២០០៦ នេះតទៅ ។ តួរលេខគំរោងចំណូល-ចំណាយថវិកា ត្រូវសរសេរ ជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

**២៧-** ក្នុងការអនុវត្តន៍សារាចរណែនាំនេះ បើក្រសួង-ស្ថាប័ន និង មន្ទីជំនាញខេត្ត-ក្រុង មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

*"ដើម្បីជូនជ្រាប"*

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

*"ដើម្បីអនុវត្ត"*

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

# គំរោងថវិកាឆ្នាំ ២០០៧

## គំរោងចំណាយថវិការយៈពេលមធ្យម

តារាង១ "ក"

| ប្រភេទចំណាយ | ២០០៤ | ២០០៥ | | ២០០៦ | | ២០០៧ | | ២០០៨ | | ២០០៩ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ជាក់ស្តែង | ជាក់ស្តែង | %កំណើន | ប៉ាន់ស្មាន | %កំណើន | គំរោង | %កំណើន | គំរោង | %កំណើន | គំរោង | %កំណើន |
| **សរុបរួមចំណាយថវិកា** (លានរៀល) | | | | | | | | | | | |
| ផលសរុបក្នុងស្រុក (លានរៀល) | 20.645.000 | 24.640.000 | 19,4% | 27.169.000 | 10,3% | 30.084.000 | 10,7% | | | | |
| % នៃផ.ស.ស | | | | | | | | | | | |
| **ក.ចំណាយចរន្ត** | | | | | | | | | | | |
| ជំពូក ៦០: ការទិញ | | | | | | | | | | | |
| ជំពូក ៦១: សេវាខាងក្រៅ | | | | | | | | | | | |
| ជំពូក ៦២: សេវាខាងក្រៅផ្សេងៗ | | | | | | | | | | | |
| ជំពូក ៦៤: បន្ទុកបុគ្គលិក | | | | | | | | | | | |
| ជំពូក ៦៦: បន្ទុកហិរញ្ញវត្ថុ | | | | | | | | | | | |
| ជំពូក ៦៥: ឧបត្ថម្ភធន និង ជំនួយសង្គម | | | | | | | | | | | |
| ជំពូក ៦៣: ពន្ធ និង អាករ | | | | | | | | | | | |
| ជំពូក ៦៧: បន្ទុកពិសេស | | | | | | | | | | | |
| ជំពូក ៦៨: ទាយជ្ជទានអោយដល់រំលស់ អចលកម្ម | | | | | | | | | | | |
| ជំពូក ០៩: ចំណាយមិនបានគ្រោងទុក | | | | | | | | | | | |
| **ខ.ចំណាយមូលធន** | | | | | | | | | | | |
| ជំពូក ១៦: ការទូទាត់ប្រាក់ខ្ចី | | | | | | | | | | | |
| ជំពូក ២០: អចលកម្មអរូបី | | | | | | | | | | | |
| ជំពូក ២១: អចលកម្មរូបី | | | | | | | | | | | |
| ជំពូក ២៣: អចលកម្មកំពុងដំណើរការ | | | | | | | | | | | |
| ជំពូក ២៦: ភាគកម្ម និង ឥណទេយ្យ ពាក់ព័ន្ធ | | | | | | | | | | | |
| ជំពូក ២៧: អចលកម្មហិរញ្ញវត្ថុផ្សេងៗ | | | | | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួង..................

**គំរោងថវិកាឆ្នាំ ២០០៧**

**ចំណូលថវិកាទូទៅរបស់រដ្ឋ**

**តារាង២ "ក"**

( រដ្ឋបាលកណ្តាល )

ឯកតា :លានរៀល

| ជំពូក | គណនី | អនុគណនី | តារាងមុខចំណូល (តាមតារាងមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៦ | | គំរោងឆ្នាំ ២០០៧ | | | បញ្ជាក់ពីមូលហេតុនៃការប្រែប្រួល |
|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | ប៉ាន់ស្មានអនុវត្ត | សរុប | រដ្ឋបាលកណ្តាល | មន្ទីរជំនាញ | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី...............ខែ................ឆ្នាំ ២០០៦

**អ្នកធ្វើតារាង**

ថ្ងៃទី...............ខែ..................ឆ្នាំ ២០០៦

**បានឃើញ និង ឯកភាព**

**រដ្ឋលេខាធិការ និង ក្រោមរដ្ឋមន្ត្រី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួង..................

**គំរោងថវិកាឆ្នាំ ២០០៧**

**ចំណាយថវិកាទូទៅរបស់រដ្ឋ**

**តារាង៣ "ក"**

( **រដ្ឋបាលកណ្តាល** )

ឯកតា :លានរៀល

| ជំពូក | គណនី | អនុគណនី | តារាងមុខចំណាយ (តាមតារាងមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៦ | | | គំរោងឆ្នាំ ២០០៧ | | | បញ្ជាក់ពីមូលហេតុនៃការប្រែប្រួល និង តម្រូវការឥណទាន |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | ឥណទានថ្មី | ចាំន់ស្មានអនុវត្ត | សរុប | រដ្ឋបាលកណ្តាល | មន្ទីរជំនាញ | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ថ្ងៃទី..............ខែ................ឆ្នាំ ២០០៦

**អ្នកធ្វើតារាង**

ថ្ងៃទី..............ខែ..................ឆ្នាំ ២០០៦

**បានឃើញ និង ឯកភាព**

**ចាងហ្វាងលេខា និង ក្រោមរដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.................

## គំរោងថវិកាឆ្នាំ ២០០៧
## បញ្ជីសរុបនៃបុគ្គលិក បៀវត្ស និង ប្រាក់បំណាច់

តារាង៤ "គ"

| អង្គភាព | សរុបរួម | | ទាយជូទានដែលកត់ត្រាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ | | | | | | | | | | | | បុគ្គលិកអណ្តែត | | បុគ្គលិកជាប់កិច្ចសន្យា | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បៀវត្ស (លានរៀល) | ចំនួនបុគ្គលិក | បុគ្គ.អចិន្ត្រៃយ៍សរុប | | ប្រភេទ "ក" | | ប្រភេទ "ខ" | | ប្រភេទ "គ" | | ប្រភេទ "ឃ" | | ផ្សេងៗ | | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក |
| | | | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | | | | |
| **សរុបរួម ( ១ + ២ )** | | | | | | | | | | | | | | | | | | |
| **១. រដ្ឋបាលកណ្តាល** | | | | | | | | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| **២. មន្ទីរជំនាញ** | | | | | | | | | | | | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួង..................

**គំរោងថវិកាឆ្នាំ ២០០៧**

**ការគ្រប់គ្រងអសន្ទារីមរដ្ឋបាល : ថ្លៃឈ្នួល ការរៀបចំ-ថែទាំ ទឹក និង អគ្គិសនី**

**តារាង៥ "ក"**

ឯកតា :លានរៀល

| អង្គភាព | សរុប | សំរាប់ប្រើប្រាស់ក្នុងរដ្ឋបាល | | | | | សំរាប់ប្រើប្រាស់ក្នុងវាសនដ្ឋាន | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | គណនី ៦១៣ ថ្លៃឈ្នួល | ការថែទាំ និង ជួសជុល | | អនុគណនី ៦០៦២ ទឹក | អនុគណនី ៦០៦១ អគ្គិសនី | គណនី ៦១៣ ថ្លៃឈ្នួល | ការថែទាំ និង ជួសជុល | | អនុគណនី ៦០៦២ ទឹក | អនុគណនី ៦០៦១ អគ្គិសនី |
| | | | គណនី ៦១៥ | អនុគណនី ២១៣២ | | | | គណនី ៦១៥ | អនុគណនី ២១៣២ | | |
| **សរុបរួម ( ១ + ២ )** | | | | | | | | | | | |
| **១. រដ្ឋបាលកណ្តាល** | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| **២. មន្ទីរជំនាញ** | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.................

គំរោងថវិកាឆ្នាំ ២០០៧

ចលនវត្ថុ-សម្ភារៈ និង សម្ភារៈការិយាល័យ

តារាង៦ "ក"

ឯកតា :លានរៀល

| អង្គភាព | សរុប | ចលនៈវត្ថុ និង សំភារៈ | | | | ក្រដាស់បោះពុម្ព និង គ្រឿងផ្គត់ផ្គង់ | |
|---|---|---|---|---|---|---|---|
| | | ការទិញ | | | ការថែទាំ | ក្រដាស់បោះពុម្ព | សំភារៈការិយាល័យ |
| | | គណនី ៦០៥ | គណនី ២១៥ | គណនី ២១៨ | គណនី ៦១៥ | អនុគណនី ៦០២១ | អនុគណនី ៦០២១ |
| **សរុបរួម ( ១ + ២ )** | | | | | | | |
| **១. រដ្ឋបាលកណ្តាល** | | | | | | | |
| ខុទ្ទកាល័យ | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| **២. មន្ទីរជំនាញ** | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួង..................

**គំរោងថវិកាឆ្នាំ ២០០៧**

**ជំពូក ៦០ ~ គណនី ៦០១ ~ អនុគណនី ៦០១៥**

**តារាង៧ "ក"**

| អង្គភាព | មធ្យោបាយ | | សរុប ទឹកប្រាក់ | ប្រេងឥន្ធនៈ (លានរៀល) | | | ប្រេងរំអិល (លានរៀល) | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រភេទមធ្យោបាយ | សរុប | | សរុប | ប្រេងសាំង EA | ប្រេងម៉ាស៊ូត DO | សរុប | ម៉ាស៊ីនសាំង | ម៉ាស៊ីនម៉ាស៊ូត |
| **សរុបរួម ( ១ + ២ )** | | | | | | | | | |
| **១. រដ្ឋបាលកណ្តាល** | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| **២. មន្ទីរជំនាញ** | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

គំរោងថវិកាឆ្នាំ ២០០៧

ចំណាយឧបត្ថម្ភសោហ៊ុយ : ជំពូក ៦២ - គណនី ៦២៤ និង ៦២៥

តារាងទី៨ "ក"

ឯកតា :លានរៀល

| អង្គភាព | សរុប | បេសកកម្មនៅក្នុងរង្វង់ខេត្ត-ក្រុង | | | បេសកកម្មឆ្លងខេត្ត-ក្រុង | | | បេសកកម្មក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ផ្សេងៗ |
| **សរុបរួម ( ១ + ២ )** | | | | | | | | | | | |
| **១. រដ្ឋបាលកណ្តាល** | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| **២. មន្ទីរជំនាញ** | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង........................

**គំរោងថវិកាឆ្នាំ ២០០៧ តាមកម្មវិធី**

**ការគ្រោងចំណាយរយៈពេលមធ្យម**

តារាង ៩

ឯកតា :លានរៀល

| កម្មវិធីសកម្មភាព | ប្រភេទនៃកម្មវិធី/សកម្មភាព (កំពុងដំណើរការ/ថ្មី) | ឆ្នាំ ២០០៦ | | | | ឆ្នាំ ២០០៧ | | | | ឆ្នាំ ២០០៨ | | | | ឆ្នាំ ២០០៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណាយចរន្ត | | ចំណាយជាមូលធន | | ចំណាយចរន្ត | | ចំណាយជាមូលធន | | ចំណាយចរន្ត | | ចំណាយជាមូលធន | | ចំណាយចរន្ត | | ចំណាយជាមូលធន | |
| | | ឥណទាន | ប្រភពឥណទាន | ឥណទាន | ប្រភពឥណទាន | តំរោងឥណទាន | ប្រភពឥណទាន | តំរោងឥណទាន | ប្រភពឥណទាន | តំរោងឥណទាន | ប្រភពឥណទាន | តំរោងឥណទាន | ប្រភពឥណទាន | តំរោងឥណទាន | ប្រភពឥណទាន | តំរោងឥណទាន | ប្រភពឥណទាន |
| សរុបរបស់ក្រសួង | | | | | | | | | | | | | | | | | |
| ក. កម្មវិធីទី១:.................................. | | | | | | | | | | | | | | | | | |
| ក.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី១:......................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី២:......................... | | | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | | | |
| ក.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | | | | | | | |
| ខ. កម្មវិធីទី២:.................................. | | | | | | | | | | | | | | | | | |
| ខ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី១:......................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី២:......................... | | | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | | | |
| ខ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | | | | | | | |
| គ. កម្មវិធីទី៣:.................................. | | | | | | | | | | | | | | | | | |
| គ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី១:......................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី២:......................... | | | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | | | |
| គ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.........................

## គំរោងថវិកាឆ្នាំ ២០០៧ តាមកម្មវិធី

## ការគ្រោងចំណាយថវិកាឆ្នាំ ២០០៧ តាមជំពូក

តារាង ១០

ឯកតា:លានរៀល

| កម្មវិធី/សកម្មភាព | ប្រភេទនៃកម្មវិធី/សកម្មភាព (កំពុងដំណើរការ/ថ្មី) | នាយកដ្ឋាន/អង្គភាពប្រតិបត្តិ | ចំនួនមន្ត្រីចូលរួម | សរុបទឹកប្រាក់ | ចំណាយចរន្ត | | | | | | ចំណាយជាមូលធន | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ជំពូក ៦០ | ជំពូក ៦១ | ជំពូក ៦២ | ជំពូក ៦៤ | ............ | ជំពូក............ (សំរាប់ខ្ទង់ចំណាយដែលមិនអាចបំបែកបានតាមកម្មវិធី) | ជំពូក ១៦ | ជំពូក ២០ | ជំពូក ២១ | ............ | ជំពូក............ (សំរាប់ខ្ទង់ចំណាយដែលមិនអាចបំបែកបានតាមកម្មវិធី) |
| សរុបរួម | | | | | | | | | | | | | | | |
| ក. កម្មវិធីទី១:.................................... | | | | | | | | | | | | | | | |
| ក.១. អនុកម្មវិធីទី១:............................ | | | | | | | | | | | | | | | |
| -សកម្មភាពទី១:.............................. | | | | | | | | | | | | | | | |
| -សកម្មភាពទី២:.............................. | | | | | | | | | | | | | | | |
| ................................................... | | | | | | | | | | | | | | | |
| ក.២. អនុកម្មវិធីទី២:............................ | | | | | | | | | | | | | | | |
| ខ. កម្មវិធីទី២:.................................... | | | | | | | | | | | | | | | |
| ខ.១. អនុកម្មវិធីទី១:............................ | | | | | | | | | | | | | | | |
| -សកម្មភាពទី១:.............................. | | | | | | | | | | | | | | | |
| -សកម្មភាពទី២:.............................. | | | | | | | | | | | | | | | |
| ................................................... | | | | | | | | | | | | | | | |
| ខ.២. អនុកម្មវិធីទី២:............................ | | | | | | | | | | | | | | | |
| គ. កម្មវិធីទី៣:.................................... | | | | | | | | | | | | | | | |
| គ.១. អនុកម្មវិធីទី១:............................ | | | | | | | | | | | | | | | |
| -សកម្មភាពទី១:.............................. | | | | | | | | | | | | | | | |
| -សកម្មភាពទី២:.............................. | | | | | | | | | | | | | | | |
| ................................................... | | | | | | | | | | | | | | | |
| គ.២. អនុកម្មវិធីទី២:............................ | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង........................

## គំរោងថវិកាឆ្នាំ ២០០៧ តាមកម្មវិធី

## ការកំណត់គោលបំណង លទ្ធផល និង សូចនាករនៃកម្មវិធី

តារាង ១១

| កម្មវិធីសកម្មភាព | ប្រភេទនៃកម្មវិធី/សកម្មភាព (កំពុងដំណើរការ/ថ្មី) | ឆ្នាំ ២០០៦ | | | | | ឆ្នាំ ២០០៧ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | លទ្ធផលក្នុងឆ្នាំ (Output) | សូចនាករនៃលទ្ធផលក្នុងឆ្នាំ (Output Indicator) | | គោលបំណង (Objective) | លទ្ធផលចុងក្រោយ (Outcome) | លទ្ធផលក្នុងឆ្នាំ (Output) | សូចនាករនៃលទ្ធផលក្នុងឆ្នាំ (Output Indicator) | | គោលបំណង (Objective) | លទ្ធផលចុងក្រោយ (Outcome) |
| | | | និសាដៅ (Target) | សំរេចបាន (Achievment) | | | | និសាដៅ (Target) | បញ្ជាក់ពីមូលហេតុនៃការប្រែប្រួល | | |
| ក្រសួង | | | | | | | | | | | |
| ក. កម្មវិធីទី១:................................ | | | | | | | | | | | |
| ក.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | |
| -សកម្មភាពទី១:........................ | | | | | | | | | | | |
| -សកម្មភាពទី២:........................ | | | | | | | | | | | |
| ............................................ | | | | | | | | | | | |
| ក.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | |
| ខ. កម្មវិធីទី២:................................ | | | | | | | | | | | |
| ខ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | |
| -សកម្មភាពទី១:........................ | | | | | | | | | | | |
| -សកម្មភាពទី២:........................ | | | | | | | | | | | |
| ............................................ | | | | | | | | | | | |
| ខ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | |
| គ. កម្មវិធីទី៣:................................ | | | | | | | | | | | |
| គ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | |
| -សកម្មភាពទី១:........................ | | | | | | | | | | | |
| -សកម្មភាពទី២:........................ | | | | | | | | | | | |
| ............................................ | | | | | | | | | | | |
| គ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក ស ក

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១៧៥ ប្រ.ក កសក.

លិខិតចូល

ថ្ងៃទី ០៤ ខែ កក្កដា 2006

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់គំរូកែសម្រួលថ្មី និង ឯកសារបន្ថែមក្នុងការនាំចូលសម្ភារៈកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម

-បានឃើញប្រកាសលេខ ២០៤ ប្រក.កសក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែប្រែឧបសម្ព័ន្ធដែលភ្ជាប់ប្រកាសលេខ ០៦៤ ប្រក.កសក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូពាក្យសុំ និង លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសម្ភារៈកសិកម្ម

-បានឃើញសារាចរណែនាំលេខ ៣៨៤ សរណ.កសក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការណែនាំ

ការអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨

-តាមសំណើរបស់ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម

# សម្រេច

**ប្រការ ១ :** អនុញ្ញាតឱ្យប្រើប្រាស់គំរូឯកសារកែសម្រួលថ្មី និង ឯកសារបន្ថែម ក្នុងការនាំចូលសម្ភារៈកសិកម្ម ដែលជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ មានដូចខាងក្រោម :

១-គំរូឯកសារកែសម្រួលថ្មី លិខិតអនុញ្ញាតនាំចូលសម្ភារៈកសិកម្ម ។

២-គំរូឯកសារបន្ថែម លិខិតប្រកាសព័ត៌មានស្តីពីសម្ភារៈកសិកម្មនាំចូល ។

៣-គំរូឯកសារបន្ថែម សលាកប័ត្រកត់ត្រាសម្ភារៈកសិកម្មនាំចូល ។

**ប្រការ ២ :** ក្រៅពីឧបសម្ព័ន្ធដែលបានកែសម្រួលថ្មី និង បន្ថែមខាងលើខ្លឹមសារប្រកាសលេខ ២០៤ ប្រក.កសក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវរក្សាទុកដដែល ។

**ប្រការ ៣ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានមន្ទីរកសិកម្មខេត្ត ក្រុង និង ប្រធានអង្គភាពក្រោមឱវាទក្រសួង ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៦

រដ្ឋមន្ត្រី

ចាន់-សារុន

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ទីចាត់ការគយ និង រដ្ឋាករ

-គ្រប់សាលាខេត្ត ក្រុង

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សាលាកប័ត្រកត់ត្រាសម្ភារៈកសិកម្ម នាំចូល

ប្រគល់ឱ្យឈ្មោះ : ..............................................................................................

ប្រធានក្រុមហ៊ុន : ..............................................................................................

តាមរយៈលិខិតអនុញ្ញាត : លេខ................................... ចុះថ្ងៃទី...................................................

នាំចូលតាមច្រក : ..............................................................................................

ទីតាំងឃ្លាំងអចិន្ត្រៃយ៍ : ..............................................................................................

..............................................................................................

ប្រភេទសម្ភារៈកសិកម្មនាំចូល : ..............................................................................................

| | | | |
|---|---|---|---|
| ១-............................ | ចំនួន.................................... | ១១-.................................... | ចំនួន.................................... |
| ២-............................ | ចំនួន.................................... | ១២-.................................... | ចំនួន.................................... |
| ៣-............................ | ចំនួន.................................... | ១៣-.................................... | ចំនួន.................................... |
| ៤-............................ | ចំនួន.................................... | ១៤-.................................... | ចំនួន.................................... |
| ៥-............................ | ចំនួន.................................... | ១៥-.................................... | ចំនួន.................................... |
| ៦-............................ | ចំនួន.................................... | ១៦-.................................... | ចំនួន.................................... |
| ៧-............................ | ចំនួន.................................... | ១៧-.................................... | ចំនួន.................................... |
| ៨-............................ | ចំនួន.................................... | ១៨-.................................... | ចំនួន.................................... |
| ៩-............................ | ចំនួន.................................... | ១៩-.................................... | ចំនួន.................................... |
| ១០-............................ | ចំនួន.................................... | ២០-.................................... | ចំនួន.................................... |

# សាលាកប័ត្រកត់ត្រាសម្ភារៈកសិកម្មនាំចូល

| កាលបរិច្ឆេទ | រាយមុខសម្ភារៈ | ឯកតា | បរិមាណ | | នៅសល់ស្តុក | មធ្យោបាយ ដឹកជញ្ជូន |
|---|---|---|---|---|---|---|
| | | | ដឹកចូល | ដឹកចេញ | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ថ្ងៃទី..................ខែ.........................ឆ្នាំ ២០០

បានត្រួតពិនិត្យ
មន្ត្រីនីតិកម្មកសិកម្ម

អ្នកកត់ត្រា
តំណាងក្រុមហ៊ុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតប្រកាសព័ត៌មាន

# ស្តីពី

# សម្ភារៈកសិកម្មនាំចូល

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.........................................ប្រធានក្រុមហ៊ុន............................................ដែលបានទទួលលិខិតអនុញ្ញាតនាំចូលសម្ភារៈកសិកម្មលេខ.................................ចុះថ្ងៃទី...........ខែ.................ឆ្នាំ ២០០ នូវប្រភេទ..................................................................ចំនួន......................................................ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សូមអនុញ្ញាតប្រកាសព័ត៌មានជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទអំពីការនាំចូលសម្ភារៈកសិកម្មទាំងនេះ ដូចខាងក្រោម :

ក~យថាប្រភេទសម្ភារៈកសិកម្ម :..................................................................................................

១-................................ចំនួន.................................៦-............................ចំនួន............................

២-................................ចំនួន.................................៧-............................ចំនួន............................

៣-................................ចំនួន.................................៨-............................ចំនួន............................

៤-................................ចំនួន.................................៩-............................ចំនួន............................

៥-................................ចំនួន.................................១០-..........................ចំនួន............................

ខ~កាលបរិច្ឆេទ/ពេលវេលានាំចូលមកដល់ចំណុចត្រួតពិនិត្យ :

ចាប់ពីថ្ងៃទី......................ខែ..........................ឆ្នាំ ២០០.....វេលាម៉ោង...............................រហូតដល់ថ្ងៃទី................ខែ........................ឆ្នាំ ២០០..... ។

គ~ទីតាំងត្រូវផ្ទេរ ឬ ទីតាំងឃ្លាំងអចិន្ត្រៃយ៍ត្រូវស្តុក : ..........................................................................

..........................................................................................................................................

..........................................................................................................................................

ឃ~ប្រភេទមធ្យោបាយដឹកជញ្ជូន : ..........................................................................................

ចំនួន.................................គ្រឿង ចំណុះ...........................................តោន/គ្រឿង ។

ង~ទីតាំងឃ្លាំងសាខាផ្សេងទៀតរបស់ក្រុមហ៊ុន(បើសិនជាមាន)ដែលត្រូវស្តុកសម្ភារៈ :.............................

..........................................................................................................................................

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទមេត្តាជ្រាប និង ចាត់មន្ត្រីជំនាញនីតិកម្មកសិកម្មដើម្បីចុះត្រួតពិនិត្យដោយក្តីអនុគ្រោះ ។

រាជធានីភ្នំពេញ,ថ្ងៃទី.............ខែ......................ឆ្នាំ ២០០

**ប្រធានក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ.................................កសក / នទក

**សម្រាប់ អ្នកទទួលលិខិតអនុញ្ញាត**

# លិខិតអនុញ្ញាត
# នាំចូលសម្ភារៈកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

